**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 12-Jan-2012, 16:00
CMS/CFO: Uch Arun

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក
ភាគីដាក់ឯកសារ: សហមេធាវីការពារក្តីរបស់លោក អៀង សារី
ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១២

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**
ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ **សាធារណៈ/Public**
ចំណាត់ថ្នាក់ប្រភេទឯកសារ
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

# បណ្តឹងសាទុក្ខរបស់លោក អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើបណ្តឹងដិតចិត្តលោកស្រីចៅក្រម SILVIA CARTWRIGHT

---

**ដាក់ដោយ៖**

**សហមេធាវីការពារក្តី:**

លោក **អាង ឧត្តម**

លោក **Michael G. KARNAVAS**

**ដាក់ជូន ៖**

**ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល:**

ចៅក្រម **គង់ ស្រីម** ជាប្រធាន

ចៅក្រម **សោម សិរីវឌ្ឍ**

ចៅក្រម **ម៉ុង មុនីចរិយា**

ចៅក្រម **យ៉ា ណារិន**

ចៅក្រម **MOTOO Noguchi**

ចៅក្រម **Agniezska KLONOWIECKA-**

**MILART**

ចៅក្រម **Chandra Nihal JAYASINGHE**

ចៅក្រមបម្រុង **ស៊ិន រិទ្ធ**

ចៅក្រមបម្រុង **Florence MUMBA**

**សហព្រះរាជអាជ្ញា**

លោកស្រី **ជា លាង**

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក អៀង សារី តាមរយៈសហមេធាវីការពារក្តីរបស់ខ្លួន (“មេធាវីការពារក្តី”) អនុលោមតាមវិធាន ១០៤(១) និង ១០៤(៤)(ឃ) នៃវិធានផ្ទៃក្នុង អ.វ.ត.ក (“វិធាន”) សូមដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើបណ្តឹងជំទាស់ចិត្តលោកស្រីចៅក្រម Silvia Cartwright (“សេចក្តីសម្រេចដែលត្រូវបានជំទាស់”)[១]។ បណ្តឹងសាទុក្ខនេះត្រូវបានធ្វើឡើងជាការចាំបាច់ ដោយសារអង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកដោយមិនត្រឹមត្រូវ និងបកស្រាយខុសចំពោះសំណើសុំឱ្យស៊ើបអង្កេតរបស់លោក អៀង សារី ពាក់ព័ន្ធនឹងការប្រាស្រ័យទាក់ទងជាមួយ *តែភាគីម្ខាង (Ex Parte)* រវាងសហព្រះរាជអាជ្ញាអន្តរជាតិ ជាមួយលោកស្រីចៅក្រម Cartwright និងអ្នកដទៃទៀត (សំណើឱ្យមានការស៊ើបអង្កេត)[២] ថាជាបណ្តឹងជំទាស់ចិត្តអនុលោមតាមវិធាន ៣៤ ដោយខកខានមិនបានស៊ើបអង្កេតទៅតាមសំណើ ចំពោះកិច្ចប្រជុំជាមួយ *តែភាគីម្ខាង (ex parte)* រវាងលោកស្រីចៅក្រម Silvia Cartwright សហព្រះរាជអាជ្ញាអន្តរជាតិលោក Andrew Cayley និងអនុប្រធានរដ្ឋបាលលោក Knut Rosandhaug ឡើយ។ ហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលតុលាការ។ ដោយសារតែមូលហេតុនេះ និងដោយសារតែសំណើសុំឱ្យស៊ើបអង្កេតត្រូវបានធ្វើឡើងដោយអនុលោមតាមវិធាន ៣៥ នោះបណ្តឹងសាទុក្ខនេះអាចទទួលយកបាន។ ដើម្បីជាប្រយោជន៍ដល់សេដ្ឋកិច្ចតុលាការ មេធាវីការពារក្តីសូមដាក់ជាឯកសារយោងនូវកថាខណ្ឌ ១ និង ២ និង ១៣ ដល់ ៣៤ នៃសំណើសុំឱ្យស៊ើបអង្កេត។

## I. មូលដ្ឋាននៃបណ្តឹងសាទុក្ខ

*ការប្រាស្រ័យទាក់ទង តែភាគីម្ខាង ត្រូវបានហាមឃាត់រវាងចៅក្រម និងភាគីណាមួយ នៅពេលដែលការប្រាស្រ័យទាក់ទងនេះបានកើតឡើងដោយពុំមានអំណាចតាមច្បាប់ ឬការយល់ព្រមពីភាគីដទៃទៀត។ អង្គជំនុំជម្រះសាលាដំបូងបានទទួលភស្តុតាងបឋម (prima facie) នៃកិច្ចប្រជុំ តែភាគីម្ខាង ដែលបានកើតឡើងរវាងលោកស្រីចៅក្រម Silvia Cartwright សហព្រះរាជអាជ្ញាអន្តរជាតិលោក Andrew Cayley និងអនុប្រធានរដ្ឋបាលលោក Knut Rosandhaug ដោយពុំមានមូលដ្ឋានតាមផ្លូវច្បាប់ ឬពុំមានការព្រមព្រៀងពី*

---

[១] សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តលោកស្រីចៅក្រម Silvia Cartwright, ចុះថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១១, ឯកសារលេខ E137/5។

[២] សំណើរបស់លោក អៀង សារី សុំឱ្យស៊ើបអង្កេតពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងជាមួយ *តែភាគីម្ខាង* រវាងសហព្រះរាជអាជ្ញាអន្តរជាតិ ជាមួយលោកស្រីចៅក្រម Cartwright និងអ្នកដទៃទៀត, ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារលេខ E137/3។

*ភាគីនានាក្នុងសំណុំរឿង ០០២ ទេ។ តើអង្គជំនុំជម្រះសាលាដំបូងមានកំហុសឬទេ ដោយបានច្រានចោលសំណើសុំឲ្យស៊ើបអង្កេតដោយមិនត្រឹមត្រូវ និងខកខានមិនបានរៀបចំស៊ើបអង្កេតទៅលើកិច្ចប្រជុំទាំងនោះ?*

## II. **ឧទ្ទិករណ៍ដោយសង្ខេប**

១. ដោយសារមេធាវីការពារក្តីលោក អៀង សារី បានបង្ហាញភ័ស្តុតាង *បឋម* *(prima facie)* រួចមក ហើយទាក់ទិននឹងកិច្ចប្រជុំជាមួយ *តែភាគីម្ខាង* *(ex parte)* រវាងលោកស្រីចៅក្រម Cartwright លោក Cayley និងលោក Rosandhaug នោះ អង្គជំនុំជម្រះសាលាដំបូងគួរតែបានស៊ើបអង្កេតចំពោះកិច្ចប្រជុំទាំងនោះ ដោយអនុលោមទៅតាមវិធាន ៣៥ វិធាន ៤១ និង វិធាន ៩៣។ អង្គជំនុំជម្រះតុលាការកំពូលគួរតែមោឃៈសេចក្តីសម្រេចដែលត្រូវបានជំទាស់នេះ និងធ្វើការស៊ើបអង្កេតចំពោះការប្រជុំ *តែភាគីម្ខាង*ទាំងនេះ ដោយអនុលោមតាមវិធាន ៣៥(២)។

២. ការប្រាស្រ័យទាក់ទង *តែភាគីម្ខាង* រវាងចៅក្រមមួយរូប ព្រះរាជអាជ្ញាមួយរូប ត្រូវបានហាមឃាត់ បើយោងតាមក្រមសីលធម៌ចៅក្រមកម្ពុជា និងនិយាមអន្តរជាតិ ប្រសិនបើការប្រាស្រ័យទាក់ទងទាំងនេះមិនបានផ្អែកលើច្បាប់ ឬបានកើតឡើងដោយពុំមានការព្រមព្រៀងពីភាគីដទៃទៀត។ ក្រមសីលធម៌ចៅក្រមនៅ អ.វ.ត.ក បានបញ្ចូលនិយាមច្បាប់ជាតិ និងអន្តរជាតិ ដូច្នេះហើយតុលាការត្រូវអនុលោមទៅតាមការហាមឃាត់ប្រឆាំងនឹងការជួបប្រាស្រ័យទាក់ទង *តែភាគីម្ខាង*។ ចៅក្រមអន្តរជាតិមិនគួរប្រកាន់យកបទដ្ឋានក្រមសីលធម៌ដោយឡែកផ្សេងពីចៅក្រមជាតិឡើយ។ កិច្ចប្រជុំជាមួយ *តែភាគីម្ខាង* *(ex parte)* រវាងលោកស្រីចៅក្រម Silvia Cartwright លោក Andrew Cayley និងលោក Knut Rosandhaug នាំឲ្យលេចឡើងនូវការជ្រៀតជ្រែកដោយចេតនាពិតប្រាកដទៅក្នុងកិច្ចការរដ្ឋបាលតុលាការ។

៣. ការទទួលខុសត្រូវក្រៅតុលាការ ឬផ្នែករដ្ឋបាលរបស់លោកស្រីចៅក្រម Cartwright និងរបស់លោក Cayley ក្តី សុទ្ធតែមិនផ្តល់យុត្តិកម្មដល់កិច្ចប្រជុំ *តែភាគីម្ខាង*ទាំងនេះទេ។ ប្រសិនបើការសម្របសម្រួលរវាងមន្ត្រីអង្គការសហប្រជាជាតិ ("អ.ស.ប") នៅ អ.វ.ត.ក ជាការចាំបាច់ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចមែន នោះការសម្របសម្រួលគួរតែត្រូវរៀបចំស្របទៅនឹងក្របខណ្ឌច្បាប់ និងបទបញ្ញត្តិនានានៅ អ.វ.ត.ក។

៤. សំណើសុំឲ្យស៊ើបអង្កេតត្រូវបានដាក់យ៉ាងត្រឹមត្រូវជាសំណើសុំឲ្យស៊ើបអង្កេត អនុលោមតាម

វិធាន ៣៥ ដោយផ្អែកលើភ័ស្តុតាង*បឋម* ដែលបានដាក់ ដោយបង្ហាញពី “ហេតុផលអាចឲ្យជឿបាន” ថា កិច្ចប្រជុំ*តែភាគីម្ខាង* អាចបានជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលតុលាការ។ សំណើសុំឲ្យស៊ើបអង្កេតបានបង្ហាញថា៖ **ក.**កិច្ចប្រជុំ*តែភាគីម្ខាង*រវាងលោកស្រីចៅក្រម Cartwright និងលោក Cayley បានកើតឡើងតាមការកំណត់យ៉ាងទៀងទាត់ **ខ.**លោក Cayley ធ្លាប់មានវត្តមាន និងបន្តមានវត្តមាននៅចំពោះមុខលោកស្រីចៅក្រម Cartwright ក្នុងសំណុំរឿង ០០២ និង **គ.**ពុំមានមូលដ្ឋានផ្លូវច្បាប់ច្បាស់លាស់ណាមួយគាំទ្រដល់កិច្ចប្រជុំ*តែភាគីម្ខាង*នេះទេ។ អនុលោមតាមវិធាន ៣៥ វិធាន ៤១ និង វិធាន ៩៣ អង្គជំនុំជម្រះសាលាដំបូងគួរតែបានបើកការស៊ើបអង្កេតមួយ។ ការខកខានមិនបានស៊ើបអង្កេត ដោយចាត់ទុកសំណើសុំឲ្យស៊ើបអង្កេតជាសំណើសុំមួយស្របតាមវិធាន ៣៤ ដែលហាក់ដូចជាបញ្ចៀសមិនឲ្យមានការស៊ើបអង្កេតនេះ អង្គជំនុំជម្រះសាលាដំបូងបានរំលោភដល់កាតព្វកិច្ចរបស់ខ្លួនក្រោមរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក កិច្ចព្រមព្រៀង និងវិធានផ្ទៃក្នុង។

## III. បញ្ហាបឋមនានា

### ក. ភាពទទួលយកបាននៃបណ្តឹងសាទុក្ខ

៥. បណ្តឹងឧទ្ធរណ៍អាចទទួលយកបានអនុវត្តតាមវិធាន ១០៤(១)[៣] ដោយសារអង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ នៅពេលអង្គជំនុំជម្រះនេះធ្វើយុត្តិកម្មចំពោះកិច្ចប្រជុំ*តែភាគីម្ខាង* និងមានកំហុសលើអង្គហេតុ ឬនិយាយម្យ៉ាងទៀតអង្គជំនុំជម្រះនេះបានរំលោភបំពានអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ដោយចាត់ទុកសំណើសុំឲ្យស៊ើបអង្កេតថាជាបណ្តឹងជំទាស់។ អង្គជំនុំជម្រះសាលាដំបូងបានធ្វើយុត្តិកម្មចំពោះកិច្ចប្រជុំ*តែភាគីម្ខាង* ដោយសន្និដ្ឋានថា កិច្ចប្រជុំបែបនេះមិនត្រូវបានហាមឃាត់ដោយក្រមសីលធម៌ចៅក្រមនៅ អ.វ.ត.ក ទេ ហើយថា កិច្ចប្រជុំបែបនេះជាការចាំ

---

[៣] វិធាន ១០៤(១) ចែងថា៖ “អង្គជំនុំជម្រះតុលាការកំពូលត្រូវសម្រេចលើបណ្តឹងសាទុក្ខ ជំទាស់ទៅនឹងសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនៃអង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកលើមូលដ្ឋាន ដូចខាងក្រោម៖ **ក.** កំហុសលើអង្គច្បាប់ដែលនាំអោយ មោឃៈ សាលក្រមលើអង្គសេចក្តី ឬ សេចក្តីសម្រេចនោះ។ ឬ **ខ.** កំហុសនៃអង្គហេតុ ដែលនាំអោយសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនោះមានភាពមិនយុត្តិធម៌។ បន្ថែមពីនេះ បណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងទៅនឹងសេចក្តីសំរេចរបស់អង្គជំនុំជម្រះសាលាដំបូងអាចធ្វើ ទៅបានដោយផ្អែកលើមូលដ្ឋាននៃការភ័ន្តច្រឡំ ដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងដែលនាំអោយប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ”។

បាច់សម្រាប់សម្របសម្រួលការងាររបស់មន្ត្រីភាគី អ.ស.ប នៅ អ.វ.ត.ក។ កិច្ចប្រជុំ*តែភាគីម្ខាង* រវាងភាគីមួយ និងចៅក្រមមួយរូប ត្រូវបានហាមឃាត់ដោយក្រមសីលធម៌ចៅក្រមកម្ពុជា និងនិយាមអន្តរជាតិ រួមទាំង សេចក្តីណែនាំនៃក្រមសីលធម៌ប្រទេសនូវែលសេឡង់ និងក្រមសីលធម៌គណៈមេធាវីប្រទេសអង់គ្លេស និងវេលស៍ ដែលអនុវត្តចំពោះលោកស្រីចៅក្រម Cartwright និងលោក Cayley[៤]។

៦. អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ ដោយខកខានមិនបានទទួលស្គាល់ថា ច្បាប់ជាធរមានបានហាមឃាត់ចំពោះកិច្ចប្រជុំ*តែភាគីម្ខាង* ដូចដែលបានកើតឡើងរវាងលោកស្រីចៅក្រម Cartwright និងលោក Cayley កន្លងមកនោះ។ មេធាវីការពារក្តីបានស្នើសុំឱ្យស៊ើបអង្កេតដើម្បីសម្រេចថា តើបញ្ហានានាដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២ ត្រូវបានយកទៅពិភាក្សានៅក្នុងកិច្ចប្រជុំរវាងលោកស្រីចៅក្រម Cartwright និងលោក Cayley (និងបុគ្គលដទៃទៀត) ឬទេ ពោលគឺថា តើមានការជ្រៀតជ្រែកដោយចេតនាពិតប្រាកដទៅក្នុងកិច្ចការរដ្ឋបាលតុលាការឬទេ[៥]។ មេធាវី ការពារក្តីមិនបានប្តឹងជំទាស់លោកស្រីចៅក្រម Cartwright ទេ[៦]។ អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសលើអង្គហេតុ ឬនិយាយម្យ៉ាងទៀត បានរំលោភបំពានលើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ដោយខកខានមិនបានពិចារណាទៅលើខ្លឹមសារនៃសំណើសុំឱ្យស៊ើបអង្កេត។

៧. សេចក្តីសម្រេចនេះអាចប្តឹងសាទុក្ខភ្លាមៗបាន អនុលោមតាមវិធាន ១០៤(៤)(ឃ) ព្រោះថាសេចក្តីសម្រេចនេះពាក់ព័ន្ធនឹងការជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ[៧]។ មេធាវីការពារក្តីស្នើឡើងថា ខុសពីការបកស្រាយរបស់អង្គបុរេជំនុំជម្រះ[៨] នៅ អ.វ.ត.ក ច្បាប់ស្តីពី

---

[៤] សំណើសុំឱ្យស៊ើបអង្កេត, កថាខណ្ឌ ១៣, ២០។

[៥] សំណើសុំឱ្យស៊ើបអង្កេត, កថាខណ្ឌ ១៥។

[៦] សំណើសុំឱ្យស៊ើបអង្កេតបានអះអាងជាក់លាក់ថា "សំណើនេះពុំមែនជាបណ្តឹងជំទាស់ទេ", សំណើសុំឱ្យស៊ើបអង្កេត, សេចក្តីផ្តើម។

[៧] វិធាន ១០៤(៤)(ឃ) ចែងថា៖ "សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដូចខាងក្រោមត្រូវបានបើកផ្លូវឱ្យប្តឹងសាទុក្ខភ្លាមៗ៖ សេចក្តីសម្រេចស្តីពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះតាមវិធាន៣៥(៦)"។

[៨] *សូមមើល* សាលដីកាលើពាក្យសុំតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងរបស់លោក អៀង សារី សម្រាប់ការប្តឹងជំទាស់ចៅក្រម Marcel Lemonde សំណុំរឿងលេខ៖ ០០២/០៧-១២-២០០៩-អវតក/អបជ(០៦), ៥, ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០១០, កថាខណ្ឌ ១១, ១៤៖ "មិនមានយុត្តាធិការដោះស្រាយលើកំហុសចៅក្រមណាម្នាក់របស់ អ.វ.ត.ក ឡើយ ...។ ដោយសារតែពាក្យសុំប្តឹងជំទាស់ចៅក្រម Lemonde គឺជាពាក្យសុំឱ្យដាក់ទណ្ឌកម្ម យើងតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ដោយផ្អែកលើ

ការបង្កើត អ.វ.ត.ក កិច្ចព្រមព្រៀង ឬវិធានផ្ទៃក្នុង ពុំមានចែងហាមឃាត់មិនឲ្យអនុវត្តវិធាន ៣៥ ប្រឆាំងនឹងសមាជិកនៃអង្គជំនុំជម្រះសាលាដំបូងខ្លួនឯងឡើយ[៩]។

៨. អភ័យឯកសិទ្ធិដែលមានចែងក្រោមច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងកិច្ចព្រមព្រៀង[១០] មិនបាន រារាំងការទទួលយកបណ្ដឹងឧទ្ធរណ៍បានទេ ដោយសារៈ **ក.**សំណូមពរពុំមានស្នើសុំឲ្យ*ដាក់ទណ្ឌកម្ម* ជាដំណោះស្រាយទេ តែគ្រាន់តែស្នើសុំឲ្យ*ស៊ើបអង្កេត* តែប៉ុណ្ណោះ និង **ខ.** អង្គជំនុំជម្រះសាលាដំបូងខ្លួនឯងបានដំណើរការប្រឆាំងនឹងបុគ្គលិកអន្តរជាតិអនុលោមតាមវិធាន ៣៥ ថ្វីបើអភ័យឯកសិទ្ធិឲ្យរួចពីដំណើរការតាមផ្លូវច្បាប់ត្រូវបានផ្ដល់ចំពោះបុគ្គលិកអន្តរជាតិ អនុលោមតាមមាត្រា ៤២ ថ្មី(២)(ក) នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងមាត្រា ២០(២)(ក) នៃកិច្ចព្រមព្រៀងក៏ដោយ[១១]។

៩. ចៅក្រមអាចរំលោភលើសិទ្ធិរបស់ជនជាប់ចោទដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ដោយពុំចាំបាច់ប្រព្រឹត្តអំពើពុករលួយ ឬមានចេតនាទុច្ចរិតនោះទេ ពោលគឺប្រឡាក់ប្រឡូសដោយភាពលម្អៀង ឬលេចឡើងនូវភាពលម្អៀង។ វាជាការខុសឆ្គងក្នុងការសន្និដ្ឋានថា យុត្តាធិការដែលពិចារណាទៅលើឥរិយាបថរបស់ចៅក្រមក្នុងសំណុំរឿងដែលខ្លួនកំពុងជំនុំជម្រះ ត្រូវបានកម្រិតជាបណ្ដឹងជិតចិត្ត

ឥរិយាបថរបស់ចៅក្រមរូបនេះ នៅក្នុងសំណុំរឿងរបស់គាត់ផ្ទាល់នោះ ដែលសហមេធាវីការពារក្ដីបានកំណត់ថា ជាការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ ហេតុដូច្នេះពាក្យសុំនេះមិនអាចទទួលយកបាន”។

[៩] ដោយពិចារណាទៅលើលក្ខណៈពិសេសដែលមានស្រាប់របស់ អ.វ.ត.ក ដែលតម្រូវដោយវិធាន ២១ នោះ វិធាន ៣៥ នៃ អ.វ.ត.ក ត្រូវតែបែងចែកឲ្យដាច់ពីវិធាន ៧៧ នៃវិធាននីតិវិធី និងភ័ស្តុតាងរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (“ICTY”)។ ខណៈដែលវិធាន ៧៧ របស់ ICTY ទាក់ទិននឹង “អំណាចដែលមានស្រាប់”របស់តុលាការអន្តរជាតិ “ក្នុងការចាត់ទុកជាការប្រមាថតុលាការ” ចំពោះអ្នកដែលជ្រៀតជ្រែកដោយចេតនាពិតប្រាកដទៅក្នុងកិច្ចការរដ្ឋបាលតុលាការ អំណានធម្មតា និងសាមញ្ញនៃវិធាន ៣៥ បង្ហាញថា កិច្ចដំណើរការនីតិវិធីអនុលោមតាមវិធាន ៣៥ នេះមិនត្រូវបានកំហិតចំពោះជនដែលត្រូវបានសង្ស័យថាប្រមាថតុលាការនោះទេ ដោយសារថា វិធាន ៣៥ មិនបាននិយាយពីបញ្ហានេះទេ។ អំណាចដែលមានស្រាប់ណាមួយរបស់ អ.វ.ត.ក ក្នុងការសន្និដ្ឋានថាជនណាម្នាក់ត្រូវទទួលខុសត្រូវចំពោះការប្រមាថតុលាការនោះគឺដាច់ស្រឡះពីអំណាចរបស់អង្គជំនុំជម្រះក្នុងការសន្និដ្ឋានថា ជនណាម្នាក់ទទួលខុសត្រូវក្នុងការជ្រៀតជ្រែកដោយចេតនាពិតប្រាកដទៅក្នុងកិច្ចរដ្ឋបាលតុលាការ អនុលោមតាមវិធាន ៣៥។

[១០] ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក, មាត្រា ៤១, ៤២ថ្មី; កិច្ចព្រមព្រៀង, មាត្រា ១៩ និង ២០។

[១១] *សូមមើល* សំណុំរឿងលេខ ០០២/១៤-១២-២០០៩-អវតក/អបជ(០៨)។

តាមវិធាន ៣៤[១២]។ គេត្រូវធ្វើការបែងចែកឲ្យច្បាស់ បើមិនដូច្នេះទេបណ្ដឹងស្របច្បាប់លើការរំលោភបំពានរបស់ចៅក្រមនៅដំណាក់កាលបន្ទាប់បង្ហំអាចនឹងត្រូវបានបដិសេធភ្លាមៗ បើសិនជាគ្មានភស្តុតាង *បឋម* ស្ដីពីអំពើជាក់លាក់នៃអំពើពុករលួយ ឬភាពលម្អៀងរបស់ចៅក្រម ដូចជាថាចៅក្រមមួយរូបប្រព្រឹត្ត *បទល្មើសជាក់ស្ដែង* (*in flagrante delicto*) ដូចជាទទួលសំណូកជាដើម។

១០. ប្រសិនបើមានការទទួលយកមែន ការបកស្រាយទៅលើវិធាន៣៥ របស់អង្គបុរេជំនុំជម្រះ បានផ្ដល់អំណាចគ្មានកំណត់ *(carte blanche)* ក្នុងការប្រព្រឹត្តដោយមិនត្រឹមត្រូវដោយដាក់កំហិតដោយតឹងរឹងដល់សិទ្ធិរបស់ភាគីក្នុងការដាក់បណ្ដឹងសាទុក្ខជាបន្ទាន់។ គេមិនអាចបកស្រាយវិធាន ៣៥ ដូច្នេះបានទេ។ វិធាន ២១ តម្រូវថា រាល់វិធានទាំងអស់ត្រូវតែបកស្រាយតាមវិធីបែបនេះ ដើម្បីការពារផលប្រយោជន៍របស់លោក អៀង សារី និងធានានូវសុចរិតភាព និងតម្លាភាពគតិយុត្តិ។ តាមពិតទៅ វិធាន ៣៥(១) អនុវត្តចំពោះ "បុគ្គល*ណាក៏ដោយ*" ដែលជ្រៀតជ្រែកដោយមានចេតនាពិតប្រាកដទៅក្នុងកិច្ចការរដ្ឋបាលតុលាការ។ វិធាន ៣៥(១) ផ្ដល់នូវបញ្ជីមិនលម្អិតមួយអំពីសកម្មភាពផ្សេងៗ ដែលអាចត្រូវបានបកស្រាយថាជាការជ្រៀតជ្រែកក្នុងរដ្ឋបាលតុលាការ[១៣]។ អង្គជំនុំជម្រះតុលាការកំពូលមានអំណាចក្នុងការអនុញ្ញាតចំពោះសំណើរដែលបាន

---

[១២] ពោលគឺ ប្រសិនបើ និងនៅពេលចៅក្រមមានផលប្រយោជន៍ផ្ទាល់ខ្លួន ឬផ្នែកហិរញ្ញវត្ថុ ឬមានទំនាក់ទំនងណាមួយនោះ ដែលវាអាចនឹងប៉ះពាល់ជាសត្យានុម័តទៅលើភាពមិនលម្អៀងរបស់ខ្លួន ឬនាំឲ្យលេចឡើងនូវភាពលម្អៀង។ *ប្រៀបធៀបទៅនឹង* សេចក្ដីសម្រេចលើករណី*ចៅក្រម* Lemonde, កថាខណ្ឌ ១១។

[១៣] វិធាន ៣៥(១) លើកឡើងនៅក្នុងផ្នែកពាក់ព័ន្ធថា "អ.វ.ត.ក អាចដាក់ទណ្ឌកម្ម ឬបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចនូវជនណាដែលជ្រៀតជ្រែកដោយចេតនាពិតប្រាកដ ក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ រួមទាំងបុគ្គលដែល"(ត្រូវគូសបញ្ជាក់បន្ថែម)។តុលាការ ICTY, វិធាន ៧៧(ក) នៃវិធាននីតិវិធី និងភស្តុតាង ក៏ចែងរៀបរាប់ពីបញ្ជីសកម្មភាពមិនលម្អិតដែលអាចជាការជ្រៀតទៅក្នុងកិច្ចការរដ្ឋបាលតុលាការដែរ។ "បញ្ជីនៃអំពើនានាដែលមានរៀបរាប់នៅក្នុងវិធាន ៧៧(ក) (i)-(v) នៃវិធាននេះមិនមែនកម្រិតតែប៉ុណ្ណឹងទេ ដែលត្រឹមតែបង្ហាញឧទាហរណ៍នៃអំពើនានាដែលជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលតុលាការ"។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* Milošević, សំណុំរឿងលេខ IT-02-54-Misc.5 និង IT-02-54-Misc.6, សេចក្ដីសម្រេចលើការផ្ដួចផ្ដើមឲ្យមានការស៊ើបអង្កេតទាក់ទិននឹងការប្រមាថតុលាការ, ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១, កថាខណ្ឌ ១១ *ដោយដកស្រង់ នៅក្នុងរឿងក្ដី ប្រឆាំងនឹង* Florence Hartman, សំណុំរឿងលេខ IT-02-54-R77.5, សាលដីកាលើការចោទប្រកាន់ពីបទប្រមាថតុលាការ, ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៩, កថាខណ្ឌ ១៩; *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* Aleksovski, សំណុំរឿង

លើកឡើងក្នុងបណ្តឹងនេះ និងធ្វើការស៊ើបអង្កេតដោយអនុលោមតាមវិធាន ៣៥[១៤]។

១១. មេធាវីការពារក្តីបានបញ្ជាក់ច្បាស់ថា សំណើសុំឱ្យស៊ើបអង្កេតត្រូវបានធ្វើឡើងអនុលោមតាមវិធាន ៣៥ និងបានបង្ហាញថា សំណើនេះបានបំពេញតាម "បទដ្ឋានដែលមានលក្ខណៈស្រាលបំផុត"[១៥] នៃ "ហេតុផលអាចឱ្យជឿបាន"[១៦] ថា ការជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលតុលាការបានកើតមានឡើងដោយសារ៖ **ក.**កិច្ចប្រជុំ*តែភាគីម្ខាង*រវាងលោកស្រីចៅក្រម Cartwright និងលោក Cayley បានកើតឡើងយ៉ាងទៀងទាត់[១៧] **ខ.**លោក Cayley ធ្លាប់មានវត្តមាន និងបន្តមានវត្តមាននៅចំពោះមុខលោកស្រីចៅក្រម Cartwright ក្នុងសំណុំរឿង ០០២[១៨] និង **គ.**ពុំមានមូលដ្ឋានផ្លូវច្បាប់ច្បាស់លាស់ណាមួយគាំទ្រដល់កិច្ចប្រជុំ*តែភាគីម្ខាង*នេះទេ[១៩]។ អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកមិនត្រឹមត្រូវ និងបានបកស្រាយខុសថា សំណុំសុំឱ្យស៊ើបអង្កេតជាបណ្តឹងដិតចិត្តតាមវិធាន ៣៤ ទៅវិញ។ ការធ្វើបែបនេះ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការច្រានចោលសំណើសុំឱ្យស៊ើបអង្កេតតាមវិធាន ៣៥ ដោយមិនបានពិចារណាឱ្យបានល្អិតល្អន់។

---

លេខ IT-95-14/1-AR77, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ Anto Nobilo ប្រឆាំងនឹងសេចក្តីសន្និដ្ឋានពីការប្រមាថតុលាការ, ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០១, កថាខណ្ឌ ៣៩។

[១៤] *សូមមើល* វិធាន ៣៥(២)៖ "នៅពេលដែល ... *អង្គជំនុំជម្រះ*មានហេតុផលជឿថា បុគ្គលណាម្នាក់អាចធ្លាប់បានប្រព្រឹត្តអំពើណាមួយ ដូចមានចែងក្នុងអនុវិធាន ១ ខាងលើ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះអាច៖ ... **ខ.**ដឹកនាំការស៊ើបសួរបន្ថែម ដើម្បីឱ្យដឹងប្រាកដថា តើមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ចាត់ការតាមនីតិវិធី ...។" (គូសបញ្ជាក់បន្ថែម)។ *សូមមើលផងដែរ* សំណុំរឿងលេខ ០០២/១៤-១២-២០០៩-អវតក/អបជ(០៨) ដែលអង្គបុរេជំនុំជម្រះបានដឹកនាំការស៊ើបអង្កេតបែបនេះ។

[១៥] បទដ្ឋានស្តីពីហេតុផលអាចឱ្យជឿបានត្រូវបានសម្រេចថាជា "បទដ្ឋានដែលមានលក្ខណៈស្រាលបំផុត"។ សាលដីកាលើកទីពីរលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី, ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារលេខ D314/1/12, កថាខណ្ឌ ៣៧។ អង្គបុរេជំនុំជម្រះក៏បានអះអាងថា៖ "វិធាន ៣៥ រួមជាមួយវិធានផ្ទៃក្នុងជាយន្តការក្នុងថែរក្សានូវសុច្ចរិតភាពក្នុងដំណើរការរបស់តុលាការ ទាំងក្នុងដំណាក់កាលស៊ើបអង្កេតក៏ដូចជាដំណាក់ការជំនុំជម្រះ។ សុច្ចរិតភាពនៃដំណើរការនេះត្រូវបានធានាតាមរយៈអនុវត្តវិធាននេះតាមផ្លូវតុលាការ នៅពេល ... អង្គជំនុំជម្រះមួយចាត់ទុកសកម្មភាពដែលប្រព្រឹត្តដោយបុគ្គលម្នាក់គម្រាមកំហែងដល់កិច្ចការរដ្ឋបាលតុលាការ"។ *ដូចខាងលើ,* កថាខណ្ឌ ៣៨។

[១៦] វិធាន ៣៥(២)។

[១៧] សំណើសុំឱ្យស៊ើបអង្កេត, កថាខណ្ឌ ៤, ៩-១០។

[១៨] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ ២៥។

[១៩] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ ២៤។

### ខ. សំណើសុំឱ្យមានសវនាការផ្ទាល់មាត់ជាសាធារណៈ

១២. មេធាវីការពារក្តីស្នើសុំឱ្យមានសវនាការផ្ទាល់មាត់ជាសាធារណៈ ដើម្បីដោះស្រាយបញ្ហានានាដែលបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខនេះ។ វិធាន ១០៩(១) បង្ហាញថា សវនាការលើបណ្តឹងសាទុក្ខនេះគួរតែត្រូវរៀបចំឡើងជាសាធារណៈ[២០]។ បណ្តឹងសាទុក្ខនេះពាក់ព័ន្ធនឹងកិច្ចការរដ្ឋបាលតុលាការ។ ពុំមានបញ្ហាណាមួយក្នុងចំណោមបញ្ហានានាដែលបានលើកឡើងមកនេះ ចាត់ទុកជាការសម្ងាត់ទេ។

## IV. សាច់សារ

១៣. នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១១ លោក Michiel Pestman ជាសហមេធាវីអន្តរជាតិការពារក្តីលោក នួន ជា បានផ្ញើសារអេឡិចត្រូនិកទៅអនុប្រធានការិយាល័យរដ្ឋបាល អ.វ.ត.ក លោក Knut Rosandhaug ដើម្បីជូនដំណឹងថា គាត់បានទទួលដំណឹងថា លោកស្រីចៅក្រម Cartwright លោក Cayley និង លោក Rosandhaug "កំពុងជួបប្រជុំគ្នាជាទៀងទាត់នៅក្នុងការិយាល័យរបស់លោកដើម្បីពិភាក្សាអំពីបញ្ហានានាដែលពាក់ព័ន្ធនឹងតុលាការនេះ"។ លោក Pestman បានស្នើសុំចង់ដឹងថា តើព័ត៌មាននេះពិតឬទេ ហើយប្រសិនបើពិតមែន តើកិច្ចប្រជុំបែបនេះធ្វើឡើងក្នុងគោលបំណងអ្វីដែលមិនឱ្យតំណាងភាគីមួយចំនួនចូលរួមផង[២១]។ ដោយពុំបានទទួលការឆ្លើយតបវិញ លោក Michael G. Karnavas ដែលជាសហមេធាវីអន្តរជាតិការពារក្តីលោក អៀង សារី (ដែលបានទទួលសារអេឡិចត្រូនិកនេះពីលោក Pestman ដែរនោះ) បានទាក់ទងសួរលោក Cayley ដើម្បីបន្តតាមដានរឿងនេះ[២២]។

---

[២០] វិធាន ១០៩(១) ចែងថា៖ "សវនាការនៃអង្គជំនុំជម្រះតុលាការកំពូលត្រូវធ្វើឡើងជាសាធារណៈ។ អង្គជំនុំជម្រះតុលាការកំពូលអាច ធ្វើសេចក្តីសម្រេចពិចារណាលើបណ្តឹងសាទុក្ខភ្លាមៗ ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍ដែលដាក់ដោយភាគីតែប៉ុណ្ណោះ"។

[២១] សារអេឡិចត្រូនិកពីលោក Pestman ផ្ញើជូនលោក Rosandhaug ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១១។

[២២] *សូមមើលឧទាហរណ៍* សារអេឡិចត្រូនិកពីលោក Karnavas ផ្ញើជូនលោក Cayley ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១១៖ "សួស្តី Andrew! ជាបឋម ខ្ញុំសូមអបអរសាទរដែលលោកបានជាប់ដំណាក់ដំបូង [សម្រាប់តំណែងជារដ្ឋអាជ្ញានៅតុលាការព្រហ្មទណ្ឌអន្តរជាតិ]។ ខ្ញុំមានជំនឿថា លោកនឹងបានទទួលតំណែងនោះមិនខាន។ ទីពីរ ដូចលោកបានជ្រាបរួចមកហើយពីដំណើរការទាំងអស់ដែលបានកើតឡើងរយៈពេលប៉ុន្មានថ្ងៃនេះនៅ អ.វ.ត.ក វាអាចជាការល្អដែរដែលលោកគួរតែឆ្លើយចំពោះសារនេះផ្ញើជូនលោក Knut នោះ។ បានកាន់តែឆាប់កាន់តែប្រសើរ! ដោយការរាប់អានពីខ្ញុំ Michael"។

១៤. នៅថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១១ លោក Rosandhaug បានឆ្លើយតបទៅលោក Pestman វិញ ដោយបានទទួលស្គាល់ថា ការប្រាស្រ័យទាក់ទង*តែភាគីម្ខាង*រវាងលោកស្រីចៅក្រម Cartwright លោក Cayley និងរូបគាត់ផ្ទាល់ បានដំណើរការចាប់តាំងពីខែ មេសា ឆ្នាំ ២០១០ មកម្ល៉េះ[២៣]។

១៥. នៅថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១១ លោក អាង ឧត្តម និងលោក Karnavas ដែលជាសហមេធាវីការពារក្តីលោក អៀង សារី បានឆ្លើយតបតាមរយៈលិខិតមួយច្បាប់ផ្ញើជូនលោក Rosandhaug។ សហមេធាវីការពារក្តីទាំងពីររូបបានផ្តល់ការសង្កេតថា៖

> ការលេចឡើងនូវកំហុសឆ្គង ជាទូទៅនឹងធ្វើឱ្យមានការព្រួយបារម្ភចំពោះកិច្ចដំណើរការនីតិវិធី នៅពេលដែលព្រះរាជអាជ្ញាមួយរូប និងចៅក្រមមួយរូបក្នុងសំណុំរឿង ០០២ មានការប្រជុំគ្នាដើម្បីពិភាក្សាតាំងតែពីបញ្ហាផ្នែករដ្ឋបាលដែលប៉ះពាល់ដល់ អ.វ.ត.ក ជាទូទៅ ...។ ដោយយោលទៅលើ*លក្ខណៈដោយឡែក* (*sui generis*) នៃតុលាការជាតិពិសេសនេះ ដែលមានជំនួយពី អ.ស.ប នោះ ការប្រៀបធៀបរវាងអ្វីដែលអាចកើតមានឡើងនៅ [តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (“ICTY”)] និងអ្វីដែលបានអនុវត្តនៅទីនេះ ពុំត្រឹមត្រូវទេ។ ប្រសិនបើជាចេតនាចង់ឱ្យមន្ត្រីខាង អ.ស.ប នៃ អ.វ.ត.ក មានការសម្របសម្រួលកាន់តែប្រសើរជាមួយទីស្នាក់ការ អ.ស.ប នោះ ហេតុអ្វីក៏មិនអញ្ជើញតំណាងមេធាវីការពារក្តី និងដើមបណ្តឹងរដ្ឋប្បវេណីឱ្យចូលរួមផង ជាពិសេសនៅពេលលោកមានសហព្រះរាជអាជ្ញាអន្តរជាតិ (ដែលជាអ្នកកំពុងចូលរួមដោយផ្ទាល់ក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២) និងចៅក្រមសមាជិកអង្គជំនុំជម្រះសាលាដំបូង (ដែលចូលរួមក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ដែលខុសពីរដ្ឋអាជ្ញា និងប្រធានតុលាការ ដូចជានៅតុលាការ ICTY ជា

---

[២៣] សារអេឡិចត្រូនិកពីលោក Rosandhaug ផ្ញើជូនលោក Pestman ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១១។ លោក Rosandhaug បានពន្យល់ថា ការផ្តួចផ្តើមឱ្យមានកិច្ចប្រជុំរវាងលោកស្រីចៅក្រម Cartwright លោក Cayley និងលោក Rosandhaug បានធ្វើឡើងដោយលោកស្រី Patricia O’Brien ដែលជាអគ្គលេខាធិការរងទទួលបន្ទុកកិច្ចការច្បាប់ និងជាមន្ត្រីច្បាប់របស់ អ.ស.ប ក្នុងអំឡុងពេលទស្សនកិច្ចរបស់លោកស្រីមក អ.វ.ត.ក នៅខែ មេសា ឆ្នាំ ២០១០។ បើតាមទស្សនៈរបស់លោក Rosandhaug “គោលបំណងគឺដើម្បីបង្កើនការផ្តោតការប្រាស្រ័យទាក់ទងគ្នារវាងមន្ត្រីភាគី អ.ស.ប នៅ អ.វ.ត.ក និងនៅទីស្នាក់ការ អ.ស.ប” ខណៈដែល “ជូនព័ត៌មានជាបន្តបន្ទាប់ដល់សមភាគីកម្ពុជា”។ គាត់បានបន្ថែមទៀតថា កិច្ចប្រជុំបែបនេះ “ជាលក្ខណៈក្រៅផ្លូវការ ចម្លងតាមគណៈកម្មាធិការសម្របសម្រួលដែលជាបទដ្ឋាននៅក្នុងតុលាការដទៃទៀតរបស់ អ.ស.ប និងតុលាការដែលគាំទ្រដល់ អ.ស.ប”។ កិច្ចប្រជុំបែបនេះ “ពាក់ព័ន្ធនឹងបញ្ហារដ្ឋបាល និងស្ថាប័ន និង ពុំពាក់ព័ន្ធនឹងខ្លឹមសារនៃសំណុំរឿងនានាដែលដាក់ជូន អ.វ.ត.ក ទេ”។ *ដូចជើងទំព័រខាងលើ*។

ដើម)       ឱ្យជួបពិភាក្សាគ្នាពីបញ្ហានានាដែលប៉ះពាល់ដល់កិច្ចការរដ្ឋបាលទូទៅនៅ អ.វ.ត.ក ...។ កិច្ចប្រជុំបែបនេះពិតជាអាចប៉ះពាល់ខ្លាំងទៅលើសំណុំរឿងដែលកំពុងដំណើរការ ដែលសហព្រះរាជអាជ្ញា និងចៅក្រមជំនុំជម្រះកំពុងចូលរួម ...។ យើងខ្ញុំយល់ថា ការទាក់ទងដែលគួរឱ្យមានការបារម្ភរវាងសមាជិកនៃ ក.ស.ព និងចៅក្រមសមាជិកនៃអង្គជំនុំជម្រះសាលាដំបូង នាំឱ្យមានការសង្ស័យពីការប្រាស្រ័យទាក់*ទងភាគីម្ខាង* [និង] មានជំនឿលើការលើកឡើងប្រកបដោយគតិបណ្ឌិតរបស់ Lord Hewart C.J. នៅក្នុង*រឿងក្តី R តទល់នឹង Sussex Justices, Ex parte McCarthy* ដែលថា៖ "យុត្តិធម៌មិនត្រឹមតែធ្វើឱ្យមានទេ តែត្រូវបង្ហាញឱ្យឃើញច្បាស់ និងពុំមានការសង្ស័យថាបានធ្វើផងដែរ" ...។ យើងខ្ញុំមើលមិនឃើញមានមូលហេតុណាមួយដែលថា កំណត់ហេតុនៃកិច្ចប្រជុំដែលបានរៀបចំកន្លងមក មិនគួរត្រូវបានផ្សព្វផ្សាយមក DSS ក្រុមមេធាវីការពារក្តី និងដើមបណ្តឹងរដ្ឋប្បវេណីនោះទេ[២៤]។

១៦. នៅថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ លោក Pestman បានផ្ញើសារអេឡិចត្រូនិកមួយច្បាប់ជូនលោកស្រីចៅក្រម Cartwright ដោយជូនដំណឹងថា មេធាវីការពារក្តីលោក នួន ជា "រង់ចាំទទួលកំណត់ហេតុនៃកិច្ចប្រជុំទាំងនេះ ដែលនឹងអនុញ្ញាតឱ្យយើងខ្ញុំសម្រេចថា តើបញ្ហាណាខ្លះត្រូវបានយកទៅពិភាក្សា ដែលតាមទស្សនៈយើងខ្ញុំគឺថា វាអាចប៉ះពាល់ [sic] ដល់សិទ្ធិសារវ័ន្តរបស់កូនក្តីយើងខ្ញុំ"។ លោក Pestman បានកត់សម្គាល់ថា មេធាវីការពារក្តីលោក នួន ជា បាន "ឃើញព័ត៌មានដែលបង្ហាញថា កិច្ចប្រជុំដទៃទៀតបានធ្វើឡើងរវាង [លោកស្រីចៅក្រម Cartwright] និងសហព្រះរាជអាជ្ញា [អន្តរជាតិ] ដោយពុំមានមន្ត្រីរដ្ឋបាល អ.ស.ប [លោក Rosandhaug]"។ លោក Pestman បានស្វែងរកការបញ្ជាក់ថា តើព័ត៌មាននេះជាការពិតឬទេ និងបើជាការពិតមែន "តើបញ្ហាអ្វីដែលត្រូវបានយកទៅពិភាក្សានៅឯកិច្ចប្រជុំទាំងនេះ?"[២៥]។

១៧. នៅថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ លោក Cayley បានផ្ញើសារអេឡិចត្រូនិកមួយច្បាប់ជូនលោក Pestman ដោយស្នើសុំឱ្យផ្តល់នូវ "មូលដ្ឋាននៃការចោទប្រកាន់ដ៏ធ្ងន់ធ្ងរដែលលោកបានធ្វើប្រឆាំងនឹងរូបខ្ញុំ"។ លោក Cayley បានអះអាងថា គាត់មានការ "ភ្ញាក់ផ្អើល" តាមរយៈលិខិតរបស់លោក អាង ឧត្តម និង លោក Karnavas ចុះថ្ងៃទី ២ ខែ វិច្ឆិកា ដោយបានអះអាងថា "មានការភូតកុហក

---

[២៤] លិខិតពីមេធាវីការពារក្តីលោក អៀង សារី ផ្ញើជូនលោក Rosandhaug, ចុះថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១១។

[២៥] លិខិតពីលោក Pestman ផ្ញើជូនលោកស្រីចៅក្រម Cartwright, ចុះថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១១។

បានកើតឡើង ហើយខ្ញុំនឹងអាចអត់ឱនឲ្យបានទេ”។ លោក Cayley បានបន្ថែមថា គាត់នឹងមិនទទួលយក “ការចោទប្រកាន់ដោយគ្មានមូលដ្ឋានច្បាស់លាស់” ដែលបានធ្វើឡើងក្នុងគោលបំណងដែលគាត់ពណ៌នាថាជា “យុទ្ធវិធីរបស់មេធាវីការពារក្តី” នោះទេ។ លោក Cayley បានបញ្ចប់សារអេឡិចត្រូនិករបស់ខ្លួនដោយស្នើឲ្យលោក Pestman “ផ្តល់មកឲ្យខ្ញុំនូវអាសយដ្ឋាននៃគណៈមេធាវីហូឡង់។ ខ្ញុំចង់ដឹងពីវិធានស្តីពីក្រមវិជ្ជាជីវៈមេធាវីរបស់លោក”[២៦]។ នៅថ្ងៃដដែលនោះ លោក Pestman បានឆ្លើយតបទៅលោក Cayley ទៅតាមសំណើរបស់គាត់[២៧]។

១៨. នៅថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ដែរ មេធាវីការពារក្តីលោក នួន ជា បានសរសេរលិខិតមួយច្បាប់ជូនលោកចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូងថា៖

> ដោយហេតុថា ការថ្លែងសេចក្តីសន្និដ្ឋានចោទប្រកាន់ក្នុងសំណុំរឿង ០០២ កាន់តែខិតជិតមកដល់ហើយនោះ យើងខ្ញុំសូមស្នើជាបន្ទាន់ដល់អង្គជំនុំជម្រះសាលាដំបូងសុំប្រកាសឲ្យដឹងនូវ៖ (i) បញ្ជីពេញលេញនូវកិច្ចប្រជុំទាំងអស់ដែលបានធ្វើឡើងរវាងលោកស្រីចៅក្រម Cartwright និងសមាជិកនានានៃការិយាល័យសហព្រះរាជអាជ្ញា និង/ឬ លោក

---

[២៦] លិខិតពីលោក Cayley ផ្ញើជូនលោក Pestman, ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១១។

[២៧] លិខិតពីលោក Pestman ផ្ញើជូនលោក Cayley, ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១១៖

> ជូនចំពោះ Andrew, បើលោកចង់ដាក់បណ្តឹងប្រឆាំងនឹងរូបខ្ញុំ ខ្ញុំសូមជូនយោបល់ឲ្យលោកទាក់ទងជាមួយគណៈមេធាវីនៅក្រុង Amsterdam។ គណៈមេធាវីនេះមានគេហទំព័រសមរម្យជាភាសាអង់គ្លេស ដែលពន្យល់ពីរបៀបដែលត្រូវធ្វើ និងបុគ្គលដែលលោកអាចពាក្យបណ្តឹងទៅបាន៖ ‘INFORMATION REGARDING THE COMPLAINT PROCEDURE AGAINST LAWYERS’: http://www.advocatenorde amsterdam.nl/item.html&objID=4696។ លោក G.J. Kemper ជាប្រធានគណៈមេធាវីនៅក្រុង Amsterdam។ ខ្ញុំនឹងចម្លងសារអេឡិចត្រូនិកនេះជូនគាត់ ដើម្បីឲ្យគាត់បានដឹងថាលោកនឹងដាក់បណ្តឹងទៅ។ ដូចដែលលោកប្រហែលជាបានដឹងរួចមកហើយគឺថា ខ្ញុំក៏ជាសមាជិកមួយរូបនៃគណៈមេធាវីនៅក្រុងភ្នំពេញដែរ។ គណៈមេធាវីនេះមានក្រមសីលធម៌មួយគួរឲ្យចាប់អារម្មណ៍ដែរ។ ខ្ញុំជឿថាឯកសារនេះនឹងមានប្រយោជន៍ដល់លោកមិនខាន។ លោក ជីវ សុងហាក់ ជាប្រធានគណៈមេធាវី។ គាត់និយាយភាសាអង់គ្លេសបានល្អ ហើយលោកអាចទាក់ទងគាត់តាមទូរស័ព្ទដៃបាន៖ [លេខទូរស័ព្ទ]។ ខ្ញុំមានការប្រជុំជាមួយគាត់នៅថ្ងៃស្អែកវេលាម៉ោង ១០ ព្រឹក។ បើលោកមានអ្វីដែលចង់ឲ្យខ្ញុំពាំនាំទៅជម្រាបគាត់ សូមឲ្យខ្ញុំបានដឹងជាមុនផង។ ពីខ្ញុំ Michiel។

Rosandhaug និង (ii) របៀបវារៈ និង/ឬ កំណត់ហេតុនៃកិច្ចប្រជុំទាំងនេះផង[២៨]។

១៩. នៅថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ លោក Rosandhaug បានឆ្លើយតបទៅនឹងលិខិតរបស់លោក អាង ឧត្តម និង លោក Karnavas ចុះថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១១។ គាត់បានកត់សម្គាល់ថា កិច្ចប្រជុំរវាងរូបគាត់ លោក Cayley និង លោកស្រីចៅក្រម Cartwright "មានលក្ខណៈក្រៅផ្លូវការ មិនអចិន្ត្រៃយ៍ និងធ្វើឡើងដើម្បីពិភាក្សាពីបញ្ហារដ្ឋបាល និងដំណើរការការងារតែប៉ុណ្ណោះ" មិនមានរៀបចំជាកំណត់ហេតុអ្វីទេ។ សំណើរបស់មេធាវីការពារក្តីក្នុងការចូលរួមក្នុងកិច្ចប្រជុំនេះ ត្រូវបានបដិសេធ[២៩]។

២០. នៅថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ *កាសែត ខឺ កម្ពុជា ដេលី* បានរាយការណ៍លើបញ្ហានេះ។ លោក Cayley ត្រូវបានគេស្រង់សំដីថា៖

> ក្នុងការឆ្លើយតបទៅនឹងក្រុមមេធាវីការពារក្តី នួន ជា និង អៀង សារី ថា៖ កិច្ចប្រជុំរៀបចំកិច្ចការរដ្ឋបាលបែបនេះបានកើតឡើងនៅតុលាការ ICC តុលាការ ICTY និង តុលាការ ICTR។ កិច្ចប្រជុំបែបនេះជារឿងធម្មតា។ ប្រសិនបើមិនមានកិច្ចប្រជុំបែបនេះទេ ស្ថាប័នទាំងនេះរួមទាំង អ.វ.ត.ក ផងនឹងរាំងស្ទះដំណើរការការងារមិនខាន។
>
> ក្នុងការឆ្លើយតបទៅនឹងលិខិតរបស់លោក Karnavas [និងលោក អាង ឧត្តម] [ចុះថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១១] ដែលបានលើកឡើងថា ប្រធាន និងរដ្ឋអាជ្ញានៃតុលាការ ICTY មិនបានចូលរួមការងារសំណុំរឿងនោះថា៖ ចំណុចនេះមិនបានឆ្លុះបញ្ចាំងការពិតទាល់តែសោះ ...។ ប្រធាន និងអនុប្រធានតុលាការ ICTY ជាចៅក្រមដែលចូលរួមដោយផ្ទាល់ទៅក្នុងសំណុំរឿង (ហើយ ប្រសិនបើលោក Karnavas តវ៉ាពីរឿងនេះ ខ្ញុំអាចលើកឧទាហរណ៍ជូនបានចាប់ពីឆ្នាំ ១៩៩៥ មក)។ ខុសពីលោក Karnavas ខ្ញុំបានបំពេញការងារនៅការិយាល័យរដ្ឋអាជ្ញានៃតុលាការ ICTY រយៈពេល ១០ ឆ្នាំមកហើយ។ ខ្ញុំដឹងពីបញ្ហានេះ[៣០]។

---

[២៨] លិខិតពីលោក Pestman លោក Victor Koppe លោក Andrew Ianuzzi និង លោក Jasper Pauw ផ្ញើជូនលោកចៅក្រម និល ណុន កម្មវត្ថុ៖ "សំណើសុំព័ត៌មានទាក់ទិននឹងជំនួបសម្ងាត់រវាងលោកស្រីចៅក្រម Cartwright លោក លោក Andrew Cayley និង/ឬ លោក Knut Rosandhaug", ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារលេខ E137។

[២៩] លិខិតពីលោក Rosandhaug ផ្ញើជូនលោក អាង ឧត្តម និងលោក Karnavas, ចុះថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១១។

[៣០] Julia Wallace, *KRT Defense Alleges Ex Parte Meetings*, ព្រឹត្តិប័ត្រព័ត៌មាន ខឺ កម្ពុជា ដេលី, ចេញផ្សាយថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១១, ទំព័រ ២។

២១. នៅថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ *កាសែត ឌឹ កម្ពុជា ដេលី* បានបោះពុម្ពផ្សាយលិខិតមួយច្បាប់ផ្ញើជូននិពន្ធនាយកពី លោក Karnavas និង លោក អាង ឧត្តម ដែលឆ្លើយតបទៅនឹងកំណត់សម្គាល់របស់ លោក Cayley នៅថ្ងៃម្សិលមិញថា៖

> នៅក្នុងបទពិសោធន៍រយៈពេល ១០ ឆ្នាំរបស់លោក Michael G. Karnavas ក្នុងនាមជាមេធាវីការពារក្តីនៅ [តុលាការ ICTY] គាត់ពុំបានដឹងនូវឧទាហរណ៍ណាមួយដែលរដ្ឋអាជ្ញាមួយរូបរៀបចំកិច្ចប្រជុំជាទៀងទាត់ជាមួយប្រធានរដ្ឋបាល និងចៅក្រមដែលកំពុងកាន់សំណុំរឿងជាមួយគ្នានោះទេ។ លោក Cayley ចូលរួមដោយផ្ទាល់ក្នុងសំណុំរឿង ០០២ ដូចជាលោកស្រីចៅក្រម Cartwright ដែរ។ នាពេលនេះ អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ដែលមានលោកស្រីចៅក្រម Cartwright ជាចៅក្រមមួយរូបដែលនេះកំពុងដំណើរការតែសំណុំរឿង ០០២ មួយប៉ុណ្ណោះ ...។ យើងខ្ញុំមានកាតព្វកិច្ចផ្នែកក្រមសីលធម៌ក្នុងការសម្លឹងមើលទៅក្នុងបញ្ហានៃការប្រាស្រ័យទាក់ទង*តែភាគីម្ខាង*ដែលបានលើកឡើង។ លោក Cayley គួរតែជ្រាបពីបញ្ហានេះ[៣១]។

២២. នៅថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ មេធាវីការពារក្តីលោក នួន ជា បានដាក់សំណើសុំព័ត៌មានទាក់ទិននឹងជំនួប*តែភាគីម្ខាង*រវាងលោកស្រីចៅក្រម Silvia Cartwright សហមេធាវីបរទេស និងអនុប្រធានរដ្ឋបាល[៣២]។ មកទល់នឹងពេលនេះ ទាំងលោកស្រីចៅក្រម Cartwright ទាំងលោក Cayley

---

[៣១] លោក អាង ឧត្តម និង លោក Michael G. Karnavas, *Andrew Cayley's Remarks 'Defensive and Deflective'*, ព្រឹត្តិប័ត្រព័ត៌មាន ឌឹ កម្ពុជា ដេលី, ចេញផ្សាយថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១១, ទំព័រ ២៦។

[៣២] សំណើសុំព័ត៌មានទាក់ទិននឹងជំនួបសម្ងាត់រវាងលោកស្រីចៅក្រម Silvia Cartwright សហមេធាវីបរទេស និងអនុប្រធានរដ្ឋបាល, ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារលេខ E137/1៖ នៅក្នុងសំណើនេះ ក្នុងចំណោមប្រការដទៃទៀត មេធាវីការពារក្តីលោក នួន ជា "ជម្រុញឲ្យអង្គជំនុំជម្រះសាលាដំបូងបញ្ជាឲ្យលោកស្រីចៅក្រម Cartwright ផ្តល់ជូនមេធាវីការពារក្តីនូវព័ត៌មានដែលបានស្នើសុំ មានដូចជា (ក) បញ្ជីនូវរាល់ការប្រជុំទាំងអស់ដែលបានធ្វើឡើងរវាងលោកស្រីចៅក្រម Cartwright ជាមួយនឹងសមាជិកនៃការិយាល័យសហព្រះរាជអាជ្ញា ... ដោយមិនគិតថា ជំនួបនោះធ្វើឡើងដោយមាន ឬមិនមានការចូលរួមពីលោក Rosandhaug ក៏ដោយ [sic] និង (ខ) របៀបវារៈ និង/ឬ កំណត់ហេតុនៃកិច្ចប្រជុំ (បើទោះជាការកត់ត្រាមិនផ្លូវការ និង/ឬ សរសេរដោយដៃក៏ដោយ) ...។ បន្ថែមពីលើនេះ មេធាវីការពារក្តីចង់ដឹងថា តើបញ្ហាលើអង្គសេចក្តី និង/ឬ បញ្ហាទាក់ទងនឹងសំណុំរឿង ០០២ ត្រូវបានយកមកពិភាក្សាក្នុងជំនួបរវាង ឬក្នុងចំណោម លោកស្រីចៅក្រម Cartwright លោក Cayley និង លោក Rosandhaug ដែរឬក៏អត់។ ពិសេសជាងនេះទៅទៀត មេធាវីការពារក្តីចង់ដឹងថា តើលោកស្រីចៅក្រម Cartwright លោក Cayley (ឬក៏សមាជិកផ្សេងទៀតនៃការិយាល័យសហព្រះរាជអាជ្ញា) និង/ឬ លោក Rosandhaug ដែលបានពិភាក្សាពីប្រធានបទខាងក្រោមនេះទេ៖ **ក.**ការបន្តជ្រៀតជ្រែកខាងនយោបាយពីរាជរដ្ឋាភិបាលនៅ អ.វ.ត.ក **ខ.**ការប៉ះពាល់

សុទ្ធតែមិនទាន់បានផ្តល់ព័ត៌មានបន្ថែមទាក់ទិននឹងបញ្ហានេះទេ។ នៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ មេធាវីការពារក្តីលោក នួន ជា បានដាក់បណ្តឹងជំទាស់ចំពោះចៅក្រម Cartwright ដែលត្រូវបានចោទប្រកាន់ថា កិច្ចប្រជុំ*តែភាគីម្ខាង* បាននាំឲ្យមាន "ការលេចចេញនូវភាពលម្អៀងដែលមិនអាចទទួលយកបាន"[៣៣]។

២៣. នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ មេធាវីការពារក្តីបានផ្សព្វផ្សាយឯកសារដែលផ្តល់គ្រាន់តែជាការគួរសមអំពីសំណើសុំឲ្យស៊ើបអង្កេតទៅអង្គជំនុំជម្រះសាលាដំបូង និងភាគីនានា។ នៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ សំណើសុំឲ្យស៊ើបអង្កេតត្រូវបានដាក់ដោយមានការកែប្រែតិចតួច ដែលមិនបានបន្ធូរបន្ថយ សម្រាល ឬកាត់បន្ថយបញ្ហានានាដែលបានលើកឡើងក្នុងឯកសារដែលផ្តល់ជូននោះទេ។ នៅក្នុងសំណើសុំឲ្យស៊ើបអង្កេត មេធាវីការពារក្តីបានស្នើថា៖

> **ក.**បញ្ជីនៃរាល់កិច្ចប្រជុំទាំងអស់ដែលលោក Cayley និងលោកស្រីចៅក្រម Cartwright បានចូលរួមក្នុងជំនួប*តែភាគីម្ខាង* ទោះជាជំនួបនោះមានការចូលរួមពីអ្នកដទៃក៏ដោយ ឲ្យតែមានកិច្ចពិភាក្សាទាក់ទងនឹងសំណុំរឿង ០០២ ដោយផ្ទាល់ ឬដោយប្រយោល និង **ខ.**អង្គហេតុ និងព័ត៌មានលម្អិតដែលពាក់ព័ន្ធទាំងអស់ទាក់ទងនឹងជំនួប*តែភាគីម្ខាង*ទាំងនោះ ក្នុងនោះមិនកំណត់ត្រឹមតែរបៀបវារៈ និង/ឬ កំណត់ហេតុនៃកិច្ចប្រជុំ (ទោះបីជាការកត់ត្រាមិនផ្លូវការ និង/ឬ សរសេរដោយដៃក៏ដោយ)[៣៤]។

មេធាវីការពារក្តីបានស្នើសុំបន្ថែមទៀតថា៖

> អង្គជំនុំជម្រះសាលាដំបូងអនុវត្តសិទ្ធិអំណាចរបស់ខ្លួនដើម្បីស៊ើបអង្កេតដោយ **ក.***កោះឲ្យ* លោក Cayley អ្នកស្រី Patricia O'Brien (អគ្គលេខាធិការរងទទួលបន្ទុកផ្នែកកិច្ចការច្បាប់ និងជាទីប្រឹក្សាផ្នែកច្បាប់របស់អង្គការសហប្រជាជាតិ) និងលោក Knut Rosandhaug និងអ្នកដទៃទៀត (ដែលពាក់ព័ន្ធ ឬមិនជាប់ពាក់ព័ន្ធជាមួយ អ.វ.ត.ក រួមទាំងតែមិនកម្រិតត្រឹមតែអ្នកការទូត និងតំណាងរបស់រដ្ឋាភិបាលបរទេស) ដែលបានចូលរួមក្នុងជំនួប*តែភាគីម្ខាង* ជាមួយលោក Cayley និងលោកស្រីចៅក្រម Cartwright

---

ដោយការជ្រៀតជ្រែកលើសំណុំរឿង ០០៣ និង ០០៤ **គ.**ការប៉ះពាល់ដោយការជ្រៀតជ្រែកលើសំណុំរឿង ០០២ **ឃ.**លទ្ធផលនៃការស៊ើបអង្កេតដោយឯករាជ្យលើការជ្រៀតជ្រែកនេះ"។ *ដូចខាងលើ,* កថាខណ្ឌ ៦-៧។

[៣៣] បណ្តឹងជំទាស់ចំពោះលោកស្រីចៅក្រម Cartwright, ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារលេខ E137/2, កថាខណ្ឌ ១៥។

[៣៤] សំណើសុំឲ្យស៊ើបអង្កេត, សេចក្តីផ្តើម (លុបជើងទំព័រខាងក្នុងអត្ថបទ)។

… ផ្តល់នូវព័ត៌មានដែលបានស្នើ និង ២.*លើកទឹកចិត្ត*ឲ្យលោកស្រីចៅក្រម Cartwright ចេញសេចក្តីថ្លែងការណ៍ផ្តល់ព័ត៌មានដែលបានស្នើ ទោះបីជាសំណើនេះមិនមែនជាការដាក់បណ្តឹងជំទាស់ក៏ដោយចុះ[៣៥]។

២៤. នៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ មេធាវីការពារក្តីបានផ្ញើលិខិតទៅទីប្រឹក្សាច្បាប់ អ.ស.ប អ្នកស្រី Patricia O'Brien[៣៦] ឯកឧត្តម សុខ អាន[៣៧] និងប្រធានគណៈកម្មាធិការរដ្ឋបាលតុលាការ ("JAC") លោកចៅក្រម គង់ ស្រ៊ីម[៣៨]។ លិខិតដែលផ្ញើជូនអ្នកស្រី O'Brien ស្នើសុំឲ្យគាត់ផ្តល់នូវសេចក្តីថ្លែងការណ៍លម្អិតពីការយល់ដឹងរបស់គាត់ចំពោះកិច្ចប្រជុំ*តែភាគីម្ខាង*ទាំងនេះ។ លិខិតដែលផ្ញើជូនឯកឧត្តម សុខ អាន គឺសាកសួរថា តើគាត់បានដឹងពីកិច្ចប្រជុំ*តែភាគីម្ខាង*ទាំងនេះឬទេ។ លិខិតដែលផ្ញើជូនលោកចៅក្រម គង់ ស្រ៊ីម សាកសួរថា ក្នុងឋានៈជាប្រធាន JAC តើគាត់បានប្រគល់សិទ្ធិអំណាច បានទទួលព័ត៌មាន និងបានទទួលលទ្ធផលពីកិច្ចប្រជុំ*តែភាគីម្ខាង*ទាំងនេះឬទេ។

២៥. នៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានចែកជូនសេចក្តីជូនដំណឹងក្រៅផ្លូវការពីចម្លើយតបរួមរបស់ខ្លួនទៅនឹងសំណើសុំឲ្យស៊ើបអង្កេត និងបណ្តឹងជំទាស់ជាបន្ទាន់របស់មេធាវីការពារក្តីលោក នួន ជា ចំពោះលោកស្រីចៅក្រម Cartwright ("ចម្លើយតបរួមរបស់សហព្រះរាជ

---

[៣៥] *ដូចជើងទំព័រខាងលើ*។

[៣៦] លិខិតពីក្រុមមេធាវីការពារក្តីលោក អៀង សារី ផ្ញើជូនអ្នកស្រី Patricia O'Brien, កម្មវត្ថុ៖ សំណើសុំការផ្តល់សេចក្តីថ្លែងការណ៍ទាក់ទិននឹងចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះសាលាដំបូងនៅ អ.វ.ត.ក លោកស្រីចៅក្រម Cartwright សហព្រះរាជអាជ្ញាអន្តរជាតិនៅ អ.វ.ត.ក លោក Andrew Cayley និងអនុប្រធានរដ្ឋបាល UNAKRT លោក Knut Rosandhaug, ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១។

[៣៧] លិខិតពីក្រុមមេធាវីការពារក្តីលោក អៀង សារី ផ្ញើជូនឯកឧត្តម សុខ អាន, កម្មវត្ថុ៖ សំណើសុំការផ្តល់សេចក្តីថ្លែងការណ៍ទាក់ទិននឹងចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះសាលាដំបូងនៅ អ.វ.ត.ក លោកស្រីចៅក្រម Cartwright សហព្រះរាជអាជ្ញាអន្តរជាតិនៅ អ.វ.ត.ក លោក Andrew Cayley និងអនុប្រធានរដ្ឋបាល UNAKRT លោក Knut Rosandhaug, ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១។

[៣៨] លិខិតពីក្រុមមេធាវីការពារក្តីលោក អៀង សារី ផ្ញើជូនលោកចៅក្រម គង់ ស្រ៊ីម, កម្មវត្ថុ៖ សំណើសុំការផ្តល់សេចក្តីថ្លែងការណ៍ទាក់ទិននឹងចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះសាលាដំបូងនៅ អ.វ.ត.ក លោកស្រីចៅក្រម Cartwright សហព្រះរាជអាជ្ញាអន្តរជាតិនៅ អ.វ.ត.ក លោក Andrew Cayley និងអនុប្រធានរដ្ឋបាល UNAKRT លោក Knut Rosandhaug, ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១។

អាជ្ញា")។ នៅថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១១ ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាត្រូវបានដាក់[៣៩]។ សហព្រះរាជអាជ្ញាបានអះអាងថា ដើម្បីបំពេញតាមបទដ្ឋានស្តីពី "ហេតុផលអាចឱ្យជឿបាន" "អង្គជំនុំជម្រះត្រូវតែរកឱ្យឃើញថា "មានភាពលម្អៀង ឬមូលហេតុជាក់ស្តែងដែលជាមូលដ្ឋាននៃជំនឿរបស់ខ្លួន""[៤០]។ សហព្រះរាជអាជ្ញាបានអះអាងថា មេធាវីការពារក្តីបាន "ខកខានមិនបានបង្ហាញឱ្យឃើញនូវមូលដ្ឋានជាក់លាក់ ដើម្បីចង្អុលបង្ហាញឱ្យឃើញនូវ*អំពើពិរុទ្ធ* ដែលថា កិច្ចប្រជុំផ្នែករដ្ឋបាល បង្កទៅជាការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ ពាក់ព័ន្ធទៅនឹង អៀង សារី ក្នុងសំណុំរឿង ០០២ ... [ហើយ] មេធាវីការពារក្តី អៀង សារី*មិនបាន*លើកឡើងនូវទឡ្ហីករណ៍ដែលថា ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់តុលាការ ត្រូវបានធ្វើឡើងដោយមាន*ចេតនាឧក្រិដ្ឋ*នោះទេ"[៤១]។

២៦. នៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១១ មេធាវីការពារក្តីបានស្នើសុំអនុញ្ញាតឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ដោយសារ*ក្នុងចំណោមប្រការដទៃទៀត* ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាបកស្រាយខុសនូវមូលដ្ឋានផ្លូវច្បាប់សម្រាប់សំណើសុំឱ្យស៊ើបអង្កេត និងខកខានមិនបានដោះស្រាយថា តើកិច្ចប្រជុំ*តែភាគីម្ខាង*រវាងលោកស្រីចៅក្រម Cartwright និង លោក Cayley រំលោភដល់ក្រម វិធាន និងសេចក្តីណែនាំជាធរមានស្តីពីសីលធម៌វិជ្ជាជីវៈឬទេ។ មេធាវីការពារក្តីបានអះអាងថា៖

> ដើម្បីបញ្ចៀសការសង្ស័យ មេធាវីការពារក្តីបានស្នើសុំអនុញ្ញាតឆ្លើយតបថា "បទដ្ឋានដែលមានលក្ខណៈស្រាលបំផុត" តម្រូវឱ្យផ្តល់នូវ "ហេតុផលអាចឱ្យជឿបាន" ដែលថាការជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលតុលាការដែលបានកើតឡើង ត្រូវបានបង្ហាញថា៖
>
> **ក.** ការពិតគឺថា កិច្ចប្រជុំ*តែភាគីម្ខាង* រវាងលោកស្រីចៅក្រម Cartwright និង លោក Cayley បានកើតឡើងជាទៀងទាត់ (សំណើ, កថាខណ្ឌ ៤, ៩-១០)។
>
> **ខ.** ការពិតគឺថា កាលពីមុនលោក Cayley (ឧទាហរណ៍ ការថ្លែងការចោទប្រកាន់កាលពីសប្តាហ៍មុន) ធ្លាប់បាន និងបន្តមានវត្តមាននៅចំពោះមុខលោកស្រី

---

[៣៩] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹង ១) សំណើជាបន្ទាន់របស់ នួន ជា សុំប្តឹងជំទាស់លោកស្រីចៅក្រម Cartwright និង ២)សំណើរបស់ អៀង សារី សុំឱ្យស៊ើបអង្កេតទៅលើការប្រាស្រ័យទាក់ទង*តែភាគីម្ខាង* រវាងសហព្រះរាជអាជ្ញាអន្តរជាតិ លោកស្រីចៅក្រម Cartwright និងអ្នកដទៃទៀត, ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១១, ឯកសារលេខ E137/4។

[៤០] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ ២៧។

[៤១] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ ២៨-២៩។

ចៅក្រម Cartwright ក្នុងសំណុំរឿង ០០២ (សំណើ, កថាខណ្ឌ ២៥)។ និង

ឃ. ការពិតគឺថា ពុំមានមូលដ្ឋានផ្លូវច្បាប់ច្បាស់លាស់សម្រាប់គាំទ្រនូវកិច្ចប្រជុំ*តែភាគីម្ខាង*នេះទេ (សំណើ, កថាខណ្ឌ ២៤)[៤២]។

...

ការរំលោភបំពានណាមួយដល់ ... ក្រមសីលធម៌ សេចក្តីណែនាំ និងកាតព្វកិច្ច នឹងត្រូវបានបកស្រាយថាបានដឹងជាមុន និងមានចេតនា។

២៧. នៅថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១១ សំណើរបស់មេធាវីការពារក្តីសុំអនុញ្ញាតឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ត្រូវបានបដិសេធដោយមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង[៤៣]។

## V. ឧត្ថិករណ៍ និងច្បាប់

២៨. រដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងកិច្ចព្រមព្រៀង តម្រូវថា កិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក ត្រូវអនុលោមតាមបទដ្ឋានយុត្តិធម៌ ភាពត្រឹមត្រូវ និងដំណើរការតាមផ្លូវច្បាប់ជាអន្តរជាតិ[៤៤]។ អង្គជំនុំជម្រះសាលាដំបូង *ត្រូវ* ធានាថា សវនាការមានភាពត្រឹមត្រូវ និងរក្សាបានតុល្យភាពរវាងសិទ្ធិរបស់ភាគីនានា[៤៥]។ ជនជាប់ចោទមានសិទ្ធិជាសារវ័ន្តក្នុងការទទួលការជំនុំជម្រះនៅចំពោះមុខតុលាការឯករាជ្យ និងមិនលម្អៀង[៤៦]។ កិច្ចប្រជុំ*តែភាគីម្ខាង* ដែលបានកើតឡើង

---

[៤២] លិខិតពីក្រុមមេធាវីការពារក្តីលោក អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងអ្នកស្រី Susan Lamb កម្មវត្ថុ៖ សំណើរបស់ អៀង សារី សុំអនុញ្ញាតឆ្លើយតបទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាចំពោះ៖ ១)បណ្តឹងជំទាស់ (?)ដិតចិត្តបន្ទាន់របស់លោក នួន ជា ចំពោះលោកស្រីចៅក្រម Cartwright និង ២)សំណើរបស់លោក អៀង សារី សុំឱ្យស៊ើបអង្កេតពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងជាមួយ*តែភាគីម្ខាង* រវាងសហព្រះរាជអាជ្ញាអន្តរជាតិ ជាមួយលោកស្រីចៅក្រម Cartwright និងអ្នកដទៃទៀត, ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១១។

[៤៣] សារអេឡិចត្រូនិកពីអ្នកស្រី Susan Lamb ផ្ញើជូនភាគីទាំងអស់, ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១១។

[៤៤] រដ្ឋធម្មនុញ្ញ, មាត្រា ៣១; ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ៣៣ថ្មី; កិច្ចព្រមព្រៀង, មាត្រា ១៣(១)។

[៤៥] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ៣៣ថ្មី; កិច្ចព្រមព្រៀង, មាត្រា ១២; វិធាន ២១(១)(ក)។

[៤៦] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ICCPR"), មាត្រា ១៤(១)។ សិទ្ធិនានាដែលត្រូវបានធានាដោយ ICCPR ត្រូវបានធានាដល់ជនជាប់ចោទទាំងអស់ដែលត្រូវបាននាំខ្លួនមកចំពោះមុខ អ.វ.ត.ក។ *សូមមើល* រដ្ឋធម្មនុញ្ញ, មាត្រា ៣១; ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ៣៣ថ្មី; កិច្ចព្រមព្រៀង, មាត្រា ១២; វិធាន ២១។ *សូមមើលផងដែរ រឿងក្តី*

រវាង លោកស្រីចៅក្រម Cartwright លោក Cayley ដែលជាសហព្រះរាជអាជ្ញានៅក្នុងសំណុំរឿង ០០២ និងលោក Rosandhaug ដោយពុំមានការអនុញ្ញាតតាមច្បាប់ ឬពុំមានការដឹង និងព្រមព្រៀងពីភាគីដទៃទៀត ប៉ះពាល់ដល់ភាពត្រឹមត្រូវនៃការជំនុំជម្រះ និងបណ្តាលឲ្យមានអតុល្យភាព ឬជាការប្រព្រឹត្តដោយមិនស្មើភាពគ្នា រវាងភាគីនានា។ តាមរយៈការបដិសេធមិនស៊ើបអង្កេតលើកិច្ចប្រជុំ*តែភាគីម្ខាង*ទាំងនេះ និងចាត់ទុកដោយមិនត្រឹមត្រូវ និងបកស្រាយខុសថា សំណើសុំឲ្យស៊ើបអង្កេតជាបណ្តឹងជិតចិត្តតាមវិធាន ៣៤ នោះ អង្គជំនុំជម្រះសាលាដំបូងបានជ្រៀតជ្រែកដោយចេតនាពិតប្រាកដទៅក្នុងកិច្ចការរដ្ឋបាលតុលាការក្នុងសំណុំរឿង ០០២ ដោយរំលោភបំពានកាតព្វកិច្ចរបស់ខ្លួនក្នុងការធានាឲ្យមានការជំនុំជម្រះក្តីដោយយុត្តិធម៌។

### ក. អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់នៅក្នុងការផ្តល់យុត្តិកម្មរបស់ខ្លួនចំពោះកិច្ចប្រជុំ*តែភាគីម្ខាង* រវាងលោកស្រីចៅក្រម Cartwright សហព្រះរាជអាជ្ញាអន្តរជាតិ លោក Cayley និងអ្នកដទៃទៀត

២៩. អង្គជំនុំជម្រះសាលាដំបូងបដិសេធមិនស៊ើបអង្កេត ដោយលើកឡើងដោយមិនត្រឹមត្រូវ ដោយពុំមានភស្តុតាង ឬឯកសារសំអាងដែលគួរឲ្យជឿជាក់បាន ថា កិច្ចប្រជុំ*តែភាគីម្ខាង*រវាងលោកស្រីចៅក្រម Cartwright លោក Cayley និង លោក Rosandhaug អាចទទួលយកបាន ដោយសារកិច្ចប្រជុំទាំងនោះចាំបាច់សម្រាប់សម្របសម្រួលមន្ត្រី អ.ស.ប នៅ អ.វ.ត.ក[៤៧]។ ក្រមខណ្ឌច្បាប់នៅ អ.វ.ត.ក ដែលត្រូវបានឆ្លុះបញ្ចាំងដោយក្រមសីលធម៌ចៅក្រមកម្ពុជា បានហាមឃាត់មិនឲ្យមានការប្រាស្រ័យទាក់ទង*តែភាគីម្ខាង* ក្នុងអំឡុងកិច្ចដំណើរការនីតិវិធីសំណុំរឿង រវាងចៅក្រម និងភាគីណាមួយ ដោយពុំមានវត្តមានភាគីមួយទៀតទេ លើកលែងតែច្បាប់អនុញ្ញាត ឬដោយមានការព្រមព្រៀងពីភាគីផ្សេងៗទៀត[៤៨]។ អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយខកខានមិនបាន

---

*រដ្ឋអាជ្ញា តទល់នឹង Furundzija,* សំណុំរឿងលេខ IT-95-17/1-A, សាលដីកា, ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០ (“សាលដីកាអង្គជំនុំជម្រះសាលាឧទ្ធរណ៍លើរឿងក្តី *Furundzija*”), កថាខណ្ឌ ១៧៧ ដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍នេះបានសម្រេចថា “សិទ្ធិមនុស្សជាសារវ័ន្តដែលត្រូវបានជំនុំជម្រះនៅចំពោះមុខតុលាការឯករាជ្យ និងមិនលម្អៀង” ត្រូវបានចាត់ទុកថាជា “ធាតុផ្សំរួម” នៃការធានាឲ្យមានការជំនុំជម្រះដោយយុត្តិធម៌។

[៤៧] សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ២១។

[៤៨] ក្រមសីលធម៌ចៅក្រមកម្ពុជា, មាត្រា ៩។

ទទួលស្គាល់ថា កិច្ចប្រជុំ*តែភាគីម្ខាង* រវាងលោកស្រីចៅក្រម Cartwright និង លោក Cayley ត្រូវបានហាមឃាត់ (ជាពិសេសដោយសារបច្ចុប្បន្ននេះ មន្ត្រីទាំងពីររូបកំពុងចូលរួមក្នុងសំណុំរឿង ០០២ នោះ ពុំមានមូលដ្ឋានផ្លូវច្បាប់ណាមួយសម្រាប់គាំទ្រកិច្ចប្រជុំបែបនេះ និងភាគីដទៃទៀតមិនមានដឹងពីកិច្ចប្រជុំទាំងនេះនោះទេ)។

៣០. កិច្ចប្រជុំ*តែភាគីម្ខាង* រវាងចៅក្រមមួយរូប និងសហព្រះរាជអាជ្ញាមួយរូប ដែលចូលរួមក្នុងសំណុំរឿងតែមួយ យ៉ាងហោចណាស់ក៏*លេចឡើង*នូវការជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលតុលាការដោយចេតនាពិតប្រាកដ។ ទោះបីជាមេធាវីការពារក្តីមិនអាចបញ្ជាក់ថា មានអ្វីមិនសមរម្យត្រូវបានពិភាក្សាក្នុងអំឡុងពេលកិច្ចប្រជុំទាំងនេះក៏ដោយ ក៏ការដែលមានការប្រជុំទាំងនេះ នាំឲ្យមានកង្វល់ថា នៅពេលពិភាក្សាពីសនិទានភាពនៃការហាមឃាត់មិនឲ្យមានកិច្ចប្រជុំបែបនេះ ដូច្នេះហើយបានជាមានសំណើសុំឲ្យស៊ើបអង្កេតនេះឡើង។ ការហាមឃាត់កិច្ចប្រជុំ*តែភាគីម្ខាង* ឆ្លុះបញ្ចាំងពីតម្រូវការឲ្យមាន "ភាពដាច់ដោយឡែកពីគ្នារវាងអ្នកដែលទទួលបន្ទុកក្នុងការចោទប្រកាន់ និងអ្នកដែលទទួលបន្ទុកការវិនិច្ឆ័យទោស"[៤៩] និងគោលការណ៍ដែលថា ចៅក្រម "ត្រូវឯករាជ្យក្នុងការបំពេញការងាររបស់ខ្លួន ហើយមិនត្រូវទទួល ឬស្វែងរកការបង្គាប់បញ្ជាពីរដ្ឋាភិបាលណាមួយ ឬពីប្រភពណាមួយផ្សេងទៀតឡើយ"[៥០]។ សនិទានភាពនេះមានកំណត់ក្នុងនិយាមអន្តរជាតិ[៥១] និងនៅក្នុងក្រមសីលធម៌ចៅក្រមកម្ពុជា ដែលហាមឃាត់កិច្ចប្រជុំ*តែភាគីម្ខាង* លើកលែងតែថាកិច្ចប្រជុំនេះត្រូវបានអនុញ្ញាតយ៉ាងច្បាស់ដោយច្បាប់ ឬនៅពេលដែលភាគីដទៃទៀតបានព្រមព្រៀង[៥២]។

៣១. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា "ក្រមសីលធម៌ចៅក្រមរបស់ អ.វ.ត.ក ពុំមែនជាក្រមសីលធម៌ចៅក្រមកម្ពុជាទេ ... ជាក្រមដែលគ្រប់គ្រងការប្រព្រឹត្តរបស់ចៅក្រមអន្តរជាតិនៅ អ.វ.ត.ក"[៥៣]។ បើទោះជាក្រមសីលធម៌ចៅក្រមរបស់ អ.វ.ត.ក ពុំចែងច្បាស់ពីការហាមឃាត់កិច្ចប្រជុំ

---

[៤៩] វិធាន ២១(១)(ក)។

[៥០] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ១០ថ្មី; កិច្ចព្រមព្រៀង, មាត្រា ៣(៣)។ *សូមមើលផងដែរ* រដ្ឋធម្មនុញ្ញ, មាត្រា ១២៨ ថ្មី។

[៥១] គោលការណ៍មូលដ្ឋានសហប្រជាជាតិស្តីពីឯករាជភាពរបស់តុលាការ, គោលការណ៍ ៤, ៦; គោលការណ៍ Bangalore ស្តីពីក្រមសីលធម៌ចៅក្រមឆ្នាំ ២០០២, គោលការណ៍ ២, បញ្ញត្តិ ២.២។

[៥២] ក្រមសីលធម៌ចៅក្រមកម្ពុជា, មាត្រា ៩។

[៥៣] សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ១៨។

*តែភាគីម្ខាង* ក្រមសីលធម៌នេះពិតជាបញ្ចូលនូវ "និយាមជាតិ និងអន្តរជាតិ"[៥៤] ដែលពិតជាហាមឃាត់ការប្រាស្រ័យទាក់ទង*តែភាគីម្ខាង*។

៣២. វិធានក្រមសីលធម៌ថ្នាក់ជាតិសម្រាប់លោកស្រីចៅក្រម Cartwright និង លោក Cayley ពិតជាហាមឃាត់ការប្រាស្រ័យទាក់ទង*តែភាគីម្ខាង*។ សេចក្តីណែនាំសម្រាប់ក្រមសីលធម៌សម្រាប់ចៅក្រមនៅប្រទេសនូវែលសេឡង់ណែនាំឲ្យលោកស្រីចៅក្រម Cartwright ត្រូវ "ចៀសវាងទំនាក់ទំនងសង្គមជាមួយអ្នកប្រតិបត្តិច្បាប់នានាដែលចូលរួមនៅក្នុងសំណុំរឿងនៅចំពោះមុខចៅក្រមរូបនោះ"[៥៥]។ លោកស្រីចៅក្រម Cartwright ក៏ត្រូវបង្ហាញ "បញ្ហាណាដែលអាចនាំឲ្យមានការជំទាស់ ... ទោះបីចៅក្រមរូបនេះបានបង្កើតមតិបឋមថា ពុំមានមូលដ្ឋានសម្រាប់ប្តឹងជិតចិត្តក៏ដោយ"[៥៦]។ លោក Cayley ត្រូវបានហាមឃាត់មិនឲ្យ៖

(ក) ចូលរួមក្នុងដំណើរការទោះបីអនុលោមតាមវិជ្ជាជីវៈរបស់ខ្លួនក៏ដោយ ឬតាមវិធីផ្សេងទៀតក៏ដោយដែល៖ ... (ii) ប៉ះពាល់ដល់រដ្ឋបាលតុលាការ ឬ (iii) ទំនងជាធ្វើឲ្យបាត់បង់ជំនឿពីសាធារណជន ទៅលើវិជ្ជាជីវៈច្បាប់ ឬកិច្ចការរដ្ឋបាលតុលាការ ឬនាំឲ្យខូចឈ្មោះដល់វិជ្ជាជីវៈច្បាប់[៥៧]។

៣៣. យោងតាមការបកស្រាយរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើក្រមសីលធម៌សម្រាប់ចៅក្រម ទោះបីនៅក្នុងយុត្តាធិការថ្នាក់ជាតិរបស់ពួកគាត់ លោកស្រីចៅក្រម Cartwright និងលោក Cayley ត្រូវបានហាមឃាត់មិនឲ្យចូលរួមនៅក្នុងការប្រាស្រ័យទាក់ទង*តែភាគីម្ខាង* (ដោយសារចៅក្រមកម្ពុជានៅក្រោមច្បាប់កម្ពុជា) ក៏ដោយ តែនៅ អ.វ.ត.ក ចៅក្រមអាចប្រាស្រ័យទាក់ទងបានដោយសេរីទៅតាមអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ដោយពុំចាំបាច់ជូនដំណឹងដល់ភាគីដទៃក្នុងសំណុំរឿង ០០២ ដែរ។ ចំណុចនេះធ្វើឲ្យមានភាពមិនសមស្របផ្នែកច្បាប់ និងជាការប្រាសចាកពីភាពយុត្តិធម៌។ អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ ដោយប៉ុនប៉ងផ្តល់យុត្តិកម្មដល់កិច្ចប្រជុំ*តែភាគីម្ខាង* តាមរយៈការអនុវត្តដោយឡែកមិនស្មើគ្នា និងមិនស៊ីសង្វាក់គ្នានូវក្រមសីលធម៌សម្រាប់ចៅក្រមរបស់ អ.វ.ត.ក។

---

[៥៤] ក្រមសីលធម៌ចៅក្រមរបស់ អ.វ.ត.ក, បុព្វកថា។

[៥៥] សេចក្តីណែនាំសម្រាប់ក្រមសីលធម៌ចៅក្រមនៅប្រទេសនូវែលសេឡង់, មាត្រា ៥០។

[៥៦] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ ៨៥-៨៦។

[៥៧] ក្រមសីលធម៌គណៈមេធាវីប្រទេសអង់គ្លេស និងវេលស៍, កថាខណ្ឌ ៣០១(ក)(ii)-(iii)។

៣៤. បើទោះជាមានភាពសមស្របនៅក្នុងការលើកឡើងរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ការសម្របសម្រួលរបស់មន្ត្រី អ.ស.ប នៃ អ.វ.ត.ក គឺជាការចាំបាច់[៥៨] ការសម្របសម្រួលបែបនេះចាំបាច់ត្រូវអនុវត្តនៅក្នុងក្របខណ្ឌច្បាប់របស់ អ.វ.ត.ក។ ផ្ទុយទៅនឹងសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា គណៈកម្មាធិការរដ្ឋបាលតុលាការ ("JAC") "មិនត្រូវបានបង្កើតឡើងដើម្បីដោះស្រាយបញ្ហានានាដែលទាក់ទិនតែទៅនឹងផ្នែកអង្គការសហប្រជាជាតិរបស់ អ.វ.ត.ក ប៉ុណ្ណោះទេ"[៥៩] ហើយថាគណៈកម្មាធិការនេះមិនមាន "សមត្ថកិច្ចផ្ដាច់មុខ ទាក់ទិននឹងការគ្រប់គ្រង និងសម្របសម្រួលផ្នែករដ្ឋបាលដែរ" គេអាចយកតាមការណែនាំពីតួនាទីស្របច្បាប់របស់គណៈកម្មាធិការនេះ។ វិធានចែងយ៉ាងច្បាស់អំពីសមាសភាពនៃគណៈកម្មាធិការរដ្ឋបាលតុលាការ[៦០] តួនាទីរបស់គណៈកម្មាធិការ[៦១] ការជួបប្រជុំនៃគណៈកម្មាធិការ[៦២] និងរបៀបធ្វើការរបស់គណៈកម្មាធិការនេះ[៦៣]។ ការសម្របសម្រួលរបស់ផ្នែកអង្គការសហប្រជាជាតិ ឬ "ក្រុម

---

[៥៨] សេចក្ដីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ២០។

[៥៩] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ ២១។

[៦០] វិធាន១៩(១)៖ "សមាសភាពរបស់គណៈកម្មាធិការរដ្ឋបាលតុលាការ ត្រូវមានចៅក្រមជាតិចំនួន៣(បី)រូប ដែលចៅក្រមមួយរូបជាប្រធាន និងចៅក្រមអន្តរជាតិចំនួន២(ពីរ)រូប ដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយកិច្ចប្រជុំពេញអង្គ។ សមាជិកជំនួសជាតិមួយរូប និងអន្តរជាតិមួយរូបរបស់គណៈកម្មាធិការត្រូវបោះឆ្នោតជ្រើសរើស នៅក្នុងកិច្ចប្រជុំពេញអង្គ ដើម្បីជំនួសសមាជិកដែលអវត្តមានទៅតាមតម្រូវការ។ សហព្រះរាជអាជ្ញាទាំងពីររូប និងប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាល អាចចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការក្នុងឋានៈជាអ្នកពិគ្រោះយោបល់បាន។ នៅពេលណាដែលសមាជិក ឬសមាជិកជំនួសណាម្នាក់របស់គណៈកម្មាធិការផ្ដល់ព័ត៌មានដល់កិច្ចប្រជុំពេញអង្គថា ខ្លួនមិនអាច ឬមានបំណងមិនចង់ធ្វើជាសមាជិករបស់គណៈកម្មាធិការតទៅទៀតទេ កិច្ចប្រជុំពេញអង្គត្រូវប្រជុំបោះឆ្នោតជ្រើសរើសសមាជិកថ្មីណាម្នាក់មកជំនួស"។

[៦១] វិធាន១៩(២)៖ "គណៈកម្មាធិការត្រូវផ្ដល់ប្រឹក្សា និងណែនាំដល់ការិយាល័យរដ្ឋបាលអំពីសកម្មភាពទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងការគាំទ្រផ្នែករដ្ឋបាល និងតុលាការដល់ការិយាល័យសហព្រះរាជអាជ្ញា ការិយាល័យសហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះ និងអង្គជំនុំជម្រះ ដោយរួមទាំងការរៀបចំ និងការអនុវត្តថវិកា"។

[៦២] វិធាន១៩(៣)៖ "គណៈកម្មាធិការត្រូវជួបប្រជុំដោយគំនិតផ្ដួចផ្ដើមរបស់ប្រធាន។ កិច្ចប្រជុំនេះត្រូវធ្វើជាសម្ងាត់។ ការចូលរួមពីចម្ងាយអាចរៀបចំធ្វើឡើងបាន តាមការចាំបាច់"។

[៦៣] វិធាន១៩(៥)៖ "គណៈកម្មាធិការត្រូវមានលេខាធិការដ្ឋានមួយជាជំនួយការ។ តាមសំណើរបស់ប្រធានគណៈកម្មាធិការ សមាជិកនៃលេខាធិការដ្ឋានរួមមាន មន្ត្រីដែលផ្ដល់មកពីអង្គជំនុំជម្រះ ឬ/និងការិយាល័យសហព្រះរាជអាជ្ញា ឬ/និងការិយាល័យសហចៅក្រមស៊ើបអង្កេត តាមករណីចាំបាច់ និងសមស្រប។ ដើម្បីសម្រេចការងាររបស់ខ្លួន គណៈកម្មាធិការរដ្ឋបាលតុលាការអាចយកអ្នកជំនាញមកជួយ ដែលជាបន្ទុករបស់អង្គជំនុំជម្រះវិសាមញ្ញ"។

ប្រឹក្សាសម្របសម្រួល”[៦៤] អាចត្រូវបានបង្កើតឡើងប្រកបដោយតម្លាភាពស្របតាមវិធានផ្ទៃក្នុង។

៣៥. អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានដោយខុសឆ្គងថា កិច្ចប្រជុំរបស់មន្ត្រី អ.ស.ប “បានអនុវត្តទៅតាមមតិយោបល់របស់ទីប្រឹក្សាច្បាប់របស់អង្គការសហប្រជាជាតិ”[៦៥]។ ការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងអនុម័តយកគោលគំនិតថា អនុសាសន៍ដែលបានផ្ដល់ដោយលោកស្រី Patricia O’Brien ទីប្រឹក្សាច្បាប់របស់ អ.ស.ប គឺលើច្បាប់ចែង។ ដោយឡែក បើតាមសំដីរបស់លោកស្រី O’Brien ក្របខណ្ឌច្បាប់របស់ អ.វ.ត.ក អាចត្រូវបានដណ្ដើមយក[៦៦]។ នៅក្នុងក្របខណ្ឌច្បាប់របស់អ.វ.ត.ក ពុំមានចំណុចណាមួយដែលមានចែងថា ទីប្រឹក្សាច្បាប់នៃអង្គការសហប្រជាជាតិ អាចណែនាំឲ្យផ្នែកអង្គការសហប្រជាជាតិនៃ អ.វ.ត.ក អនុវត្តការងារដោយនៅក្រៅវិសាលភាពនៃក្របខណ្ឌច្បាប់នៃ អ.វ.ត.ក ឡើយ។

៣៦. ដោយពុំមានសេចក្ដីថ្លែងការណ៍ជាផ្លូវការណាមួយពីសំណាក់លោកស្រីចៅក្រម Cartwright ឬលោក Cayley ក្ដី[៦៧] អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា “កិច្ចប្រជុំរវាងលោកស្រីចៅក្រម Cartwright សហព្រះរាជអាជ្ញាអន្តរជាតិ និងអនុប្រធានការិយាល័យរដ្ឋបាល ត្រូវបានយកគំរូក្រៅផ្លូវការតាមតុលាការ ICTR តុលាការ ICTY និង តុលាការ ICC ដែលកិច្ចប្រជុំនេះត្រូវបានកែសម្រួលឲ្យស្របទៅនឹងបរិបទជាក់លាក់របស់អ.វ.ត.ក”[៦៨]។ កិច្ចប្រជុំរវាងលោកស្រីចៅក្រម Cartwright និង លោក Cayley នៅអ.វ.ត.ក មិនអាចយកទៅប្រៀបធៀបនឹងក្រុម

---

[៦៤] សេចក្ដីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ១៩៖ “ក្រុមប្រឹក្សាសម្របសម្រួលទាំងនេះ...”។

[៦៥] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ២០។

[៦៦] គួរកត់សម្គាល់ថា កាលពីមុនលោកស្រី O’Brien បានគាំទ្រចំពោះការខកខានរបស់អង្គការសហប្រជាជាតិ ក្នុងការស៊ើបអង្កេតទៅលើការព្រួយបារម្ភអំពីការជំនុំជម្រះប្រកបដោយយុត្តិធម៌នៅអ.វ.ត.ក ពាក់ព័ន្ធនឹងសំណុំរឿង០០៣ និង០០៤ ដោយផ្អែកលើមូលដ្ឋានថា ការស៊ើបអង្កេតទៅក្នុងការចោទប្រកាន់អំពីការជ្រៀតជ្រែកផ្នែកនយោបាយ“អាចធ្វើឲ្យរង្គោះរង្គើដល់សំណុំរឿង០០២ [ហើយ] មេធាវីការពារក្ដីអាចចុះមូលដ្ឋានមួយថ្ងៃចំពោះបញ្ហានេះ’” Julia Wallace, *នួន ជា នាំយកបទចោទអំពីការជ្រៀតជ្រែកទៅតុលាការ (Nuon Chea Takes Meddling Charge to Court), ព្រឹត្តិប័ត្រព័ត៌មាន ខឹ កម្ពុជា ដេលី,* ចេញផ្សាយថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ ទំព័រ១ និង៣០។

[៦៧] ផ្ទុយពីអនុសាសន៍របស់មេធាវីការពារក្ដី ដូចមានលើកឡើងក្នុងសំណើសុំឲ្យស៊ើបអង្កេត ទាំងលោកស្រីចៅក្រម Cartwright និងលោក Cayley គ្មានបានចេញនូវសេចក្ដីថ្លែងការណ៍ជាផ្លូវការអ្វីមួយឡើយ។ *សូមមើល* សំណើសុំឲ្យស៊ើបអង្កេត កថាខណ្ឌ៣៣។

[៦៨] *ដូចជើងទំព័រខាងលើ។*

ប្រឹក្សាសម្របសម្រួលនៅតុលាការ ICTR តុលាការ ICTY និង តុលាការ ICC បានឡើយ។ ទីមួយ ដូចបានកត់សម្គាល់ដោយអង្គជំនុំជម្រះសាលាដំបូងរួចមកហើយគឺថា វិធាន និងបញ្ញត្តិនៅតុលាការ ICTR តុលាការ ICTY និង តុលាការ ICC មានចែងពីក្រុមប្រឹក្សាសម្របសម្រួល[៦៩]។ កិច្ចប្រជុំរវាងលោកស្រីចៅក្រម Cartwright និងលោក Cayley ពុំមានចែងក្នុងក្របខណ្ឌច្បាប់របស់ អ.វ.ត.ក ឡើយ។ ទីពីរ ប្រធានតុលាការ ICTR តុលាការ ICTY និង តុលាការ ICC ពុំមែនជាសមាសភាពក្នុងអង្គជំនុំជម្រះ ក្នុងរឿងក្ដី ដែលរដ្ឋអាជ្ញារូបនោះធ្លាប់មានវត្តមាន និងបន្តមានវត្តមាននៅចំពោះប្រធានតុលាការទាំងនោះឡើយ។ នៅ អ.វ.ត.ក លោកស្រីចៅក្រម Cartwright ចូលរួមតែក្នុងសំណុំរឿង ០០២ ប៉ុណ្ណោះ។ លោក Cayley ធ្លាប់មានវត្តមាន និងបន្តមានវត្តមាននៅចំពោះមុខលោកស្រីចៅក្រម Cartwright តទៅទៀត។

៣៧. អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានដោយខុសឆ្គងថា លោកស្រីចៅក្រម Cartwright និងលោក Cayley មាន "ការទទួលខុសត្រូវខាងក្រៅតុលាការ និងការទទួលខុសត្រូវផ្នែករដ្ឋបាល ដ៏សំខាន់" ដែលចាំបាច់ដើម្បីធានាថា ផ្នែកអន្តរជាតិរបស់ អ.វ.ត.ក មានធនធាន និងការគាំទ្រចាំបាច់ ដើម្បីបំពេញអាណត្តិការងាររបស់ខ្លួន[70]។ ការទទួលខុសត្រូវខាងក្រៅតុលាការ និងការទទួលខុសត្រូវផ្នែករដ្ឋបាលទាំងនេះ មិនតម្រូវឲ្យមានកិច្ចប្រជុំ*តែភាគីម្ខាង* រវាងលោកស្រីចៅក្រម Cartwright និង លោក Cayley នោះទេ។ វិធាន៩(១)ចែងថា៖ "ការិយាល័យរដ្ឋបាលត្រូវជួយ គាំទ្រដល់ការបំពេញការងាររបស់អង្គជំនុំជម្រះ ការិយាល័យសហព្រះរាជអាជ្ញា ការិយាល័យសហចៅក្រមស៊ើបអង្កេត និងកិច្ចប្រជុំពេញអង្គ និងត្រូវទទួលខុសត្រូវចំពោះកិច្ចការរដ្ឋបាល និងការផ្ដល់សេវាកម្មរបស់ស្ថាប័នទាំងនោះ"។ ការទទួលខុសត្រូវផ្នែករដ្ឋបាលស្ថិតក្នុងបន្ទុករបស់អង្គភាពនីមួយៗ និងការិយាល័យរដ្ឋបាល។ ដើម្បីបំពេញការទទួលខុសត្រូវក្រៅតុលាការ និងការទទួលខុសត្រូវផ្នែករដ្ឋបាល វិធានផ្ទៃក្នុងពុំតម្រូវថា សហព្រះរាជអាជ្ញាអន្តរជាតិ និងលោកស្រីចៅក្រម Cartwright ជួបប្រជុំជាមួយ អនុប្រធានរដ្ឋបាល*តែភាគីម្ខាង* ឡើយ។

---

[៦៩] វិធាន២៣ *ក្ងួន* (ខ) របស់តុលាការ ICTR។ វិធាន២៣ *ក្ងួន* (ខ) របស់តុលាការ ICTY។ បញ្ញត្តិ ៣(២)របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

[៧០] សេចក្ដីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ២០។

៣៨. យោងតាមអង្គជំនុំជម្រះសាលាដំបូង អ.វ.ត.ក គឺជា "តុលាការគំរូ"មួយ[៧១] ដែលនឹងជួយ "ជំរុញឲ្យមានការធានានូវឯករាជ្យភាព និងសុចរិតភាពនៅក្នុងស្ថាប័នតុលាការ"[៧២] នៅកម្ពុជា។ ប្រសិនបើ អ.វ.ត.ក ជាតុលាការគំរូនោះ តុលាការនេះគួរតែដំណើរការទៅដោយមានតម្លាភាព និងស្របទៅតាមបទដ្ឋានជំនុំជម្រះប្រកបដោយយុត្តិធម៌ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ និងជាតិ។ ដោយមានការហាមប្រាមទាំងក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ មិនឲ្យមានជំនួប*តែភាគីម្ខាង* ដែលកើតឡើងដោយគ្មានអំណាចផ្នែកច្បាប់ ឬការព្រមព្រៀងរបស់ភាគីផ្សេងទៀតក្នុងរឿងក្តី និងការលេចឡើងនូវការជ្រៀតជ្រែកដោយចេតនាពិតប្រាកដទៅក្នុងកិច្ចការរដ្ឋបាលតុលាការ ដែលកើតចេញពីជំនួបបែបនេះផងនោះ អង្គជំនុំជម្រះសាលាដំបូងគួរតែបានស៊ើបអង្កេតអំពីលក្ខណៈនៃជំនួបទាំងនេះ។

៣៩. អង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា ពុំត្រូវមានការស៊ើបអង្កេតបន្ថែមទៀតឡើយ ដោយហេតុថាសារអេឡិចត្រូនិកមួយដែលបានផ្ញើជូនដោយលោក Rosandhaug ទៅភាគីនានា មានភាពគ្រប់គ្រាន់ហើយក្នុងការឆ្លើយតបទៅនឹងការព្រួយបារម្ភរបស់មេធាវីការពារក្តី[៧៣]។ ការបដិសេធដោយចេតនារបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការស៊ើបអង្កេតអំពីកិច្ចប្រជុំ*តែភាគីម្ខាង*ទាំងនេះ ដែលដូច្នេះអនុញ្ញាតឲ្យចៅក្រម Cartwright និង លោក Cayley បន្តជួបប្រជុំគ្នាតទៅទៀតដោយគ្មានការដឹងឮ ឬវត្តមានរបស់ភាគីផ្សេងៗទៀតក្នុងសំណុំរឿង០០២ បង្កើតបានជាការជ្រៀតជ្រែកដោយចេតនាពិតប្រាកដទៅក្នុងកិច្ចការរដ្ឋបាលតុលាការ។ តាមរយៈការចេញសេចក្តីសម្រេចដែល ត្រូវបានជំទាស់នេះ អង្គជំនុំជម្រះសាលាដំបូងបានបោះបង់ចោលភារកិច្ចរបស់នៅក្រោមរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក កិច្ចព្រមព្រៀង និងវិធានផ្ទៃក្នុង ក្នុងការធានានូវការជំនុំជម្រះ ប្រកបដោយតុល្យភាព និងយុត្តិធម៌[៧៤]។

---

[៧១] សេចក្តីសម្រេចលើបណ្តឹងរបស់លោក អៀង សារី ដែលប្តឹងជំទាស់ចំពោះលោកចៅក្រម និល ណុន និងសំណើពាក់ព័ន្ធផ្សេងៗ ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ E5/3 កថាខណ្ឌ១៤។

[៧២] *ដូចដើងទំព័រខាងលើ។*

[៧៣] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ២០។ *សូមមើលផងដែរ* ប្រតិចារឹកនៃការជំនុំជម្រះ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារលេខ E1/13.1 ទំព័រ១៤ ដែលចៅក្រមប្រធាន និល ណុន ថ្លែងថា៖ "អង្គជំនុំជម្រះសូមជូនដំណឹងដល់ភាគីទាំងអស់ថា កន្លងមក អនុប្រធានការិយាល័យរដ្ឋបាលបានឆ្លើយតបទៅនឹងសំណើនេះរួចហើយ"។

[៧៤] រដ្ឋធម្មនុញ្ញ មាត្រា៣១។ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា៣៣ថ្មី។ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា១២-១៣។ វិធាន២១ នៃវិធានផ្ទៃក្នុង។

## ខ. អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គហេតុ ឬបើមិនដូច្នេះទេ បានបំពានឆន្ទានុសិទ្ធិរបស់ខ្លួនដោយកំណត់សំណើសុំឲ្យស៊ើបអង្កេតដោយខុសឆ្គង និងបានបដិសេធសំណើនេះ

៤០. អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានដោយខុសឆ្គងថា "ដោយសារតែញត្តិរបស់អៀង សារី មានខ្លឹមសារជាបណ្តឹងជំទាស់ចិត្ត អង្គជំនុំជម្រះសាលាដំបូងចាត់ទុកថា បណ្តឹងនេះបានផ្អែកលើវិធាន ៣៥នៃវិធានផ្ទៃក្នុងដោយពុំត្រឹមត្រូវ"[៧៥]។ សំណើសុំឲ្យស៊ើបអង្កេត *ជាបឋម* ជាសំណើសុំឲ្យស៊ើបអង្កេត។ សំណើនេះបានបំពេញទៅតាមកម្រិតនៃលក្ខខណ្ឌតម្រូវស្តីពីភ័ស្តុតាងនៃវិធាន ៣៥ ដោយបង្ហាញអំពី "ហេតុផលអាចឲ្យជឿបាន" ថា ការជ្រៀតជ្រែកដោយចេតនាពិតប្រាកដមួយទៅក្នុងកិច្ចការរដ្ឋបាលតុលាការបានកើតមានឡើង។ អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គហេតុ ឬបើមិនដូច្នេះទេ បានបំពានឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការចាត់ទុកដោយមិនត្រឹមត្រូវ និងបកស្រាយខុសចំពោះសំណើសុំឲ្យស៊ើបអង្កេត និងក្រោយមកទៀតបានបដិសេធសំណើនេះ។ វាហាក់ដូចជាថា អង្គជំនុំជម្រះធ្វើបែបនេះ ក្នុងគោលបំណងគេចចេញពីការគោរពតាមវិធានផ្ទៃក្នុង និងពីការរៀបចំស៊ើបអង្កេត ដែលអាស្រ័យទៅលើលទ្ធផលនៃការស៊ើបអង្កេតនេះ អាចនាំឲ្យមានបណ្តឹងជំទាស់ចិត្តតាមវិធាន៣៤។

៤១. ប្រសិនបើអង្គជំនុំជម្រះសាលាកំពូលឃើញថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដោយចាត់ទុកសំណើសុំឲ្យស៊ើបអង្កេតជាបណ្តឹងជំទាស់ចិត្តនោះ មេធាវីការពារក្តីស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលអនុវត្តតាមយុត្តិសាស្ត្រនៅតុលាការ ICTY អំពីបទដ្ឋានសម្រាប់ការបំពានឆន្ទានុសិទ្ធិ។ ក្នុងរឿងក្តី *Prlić* និង *អ្នកផ្សេងទៀត* អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY បានសម្រេចថា ការបំពានឆន្ទានុសិទ្ធិបានកើតឡើង ដែលសេចក្តីសម្រេចដែលត្រូវបានជំទាស់ មានភាព "អយុត្តិធម៌ និងមិនសមហេតុយ៉ាងខ្លាំង... [ក្នុងនោះ] អង្គជំនុំជម្រះសាលាដំបូង បានផ្តល់ទម្ងន់ទៅលើកត្តាមិនពាក់ព័ន្ធ ឬប្រយោល ឬខកខានមិនបានផ្តល់ទម្ងន់ ឬមិន

---

[៧៥] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ១២។ *សូមមើលផងដែរ ជើងទំព័រខាងលើ* កថាខណ្ឌ១៩៖ "សំណើរបស់មេធាវីការពារក្តី ពុំបានបំពេញនូវកម្រិតនៃលក្ខខណ្ឌតម្រូវស្តីពីភ័ស្តុតាង ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង៣៤"។ *ជើងទំព័រខាងលើ* កថាខណ្ឌ២២៖ "ដោយសារតែមូលដ្ឋានចំពោះបណ្តឹងជំទាស់ចិត្តចៅក្រម មិនអាចបង្កើតឡើងតាមរយៈការចោទប្រកាន់អំពីការប្រព្រឹត្តិខុសឆ្គង..."

បានផ្ដល់ទម្ងន់គ្រប់គ្រាន់ទៅលើកត្តាពាក់ព័ន្ធផ្សេងៗ”[៧៦]។ ក្នុងករណីនេះ អង្គជំនុំជម្រះសាលាដំបូងបានបំពានឆន្ទានុសិទ្ធិរបស់ខ្លួន ដោយខកខានមិនបានផ្ដល់ទម្ងន់សោះឡើយទៅលើខ្លឹមសារក្នុងសំណើសុំឱ្យស៊ើបអង្កេត ដែល*ជាបឋម* ជាសំណើសុំឱ្យស៊ើបអង្កេតលើជំនួប*តែភាគីម្ខាង* រវាងលោកស្រីចៅក្រម Cartwright លោក Cayley និងអ្នកផ្សេងៗទៀត។ អង្គជំនុំជម្រះសាលាដំបូងបានចាត់ទុកដោយមិនត្រឹមត្រូវ និងបកស្រាយខុសចំពោះសំណើសុំឱ្យស៊ើបអង្កេតយ៉ាងអយុត្តិធម៌ និងដោយភ័ន្តច្រឡំ ដោយចាត់ទុកសំណើនេះថាដូចគ្នាទៅនឹងបណ្ដឹងជិតចិត្ត ដែលដាក់ដោយក្រុមមេធាវីការពារក្ដីលោក នួន ជា[៧៧] ដោយពុំបានបែងចែករវាងឯកសារទាំងនេះឡើយ។

៤២. *ក្នុងចំណោមបញ្ហាផ្សេងៗទៀត* វិធាន ៣៥ ចែងថា នៅពេលដែលអង្គជំនុំជម្រះ “[មាន] ហេតុផលជឿថា បុគ្គលណាម្នាក់អាចធ្លាប់បានប្រព្រឹត្តិអំពើណាមួយ ដូចចែងក្នុង [វិធាន៣៥(១)]” អង្គជំនុំជម្រះ “ដឹកនាំការស៊ើបសួរបន្ថែម ដើម្បីឱ្យដឹងប្រាកដថា តើមានមូលដ្ឋានគ្រប់គ្រាន់សម្រាប់ចាត់ការតាមនីតិវិធី”[៧៨]។ ក្នុងសំណើសុំឱ្យស៊ើបអង្កេត មេធាវីការពារក្ដីបានស្នើសុំបញ្ជីនៃជំនួបទាំងអស់ដែលលោក Cayley និង លោកស្រីចៅក្រម Cartwright បានចូលរួមក្នុងការប្រាស្រ័យទាក់ទង*តែភាគីម្ខាង* និងរាល់អង្គហេតុពាក់ព័ន្ធ និងព័ត៌មានលំអិត ពាក់ព័ន្ធនឹងកិច្ចប្រជុំ*តែភាគីម្ខាង* ទាំងនោះ ក្នុងចំណោមនោះគឺ របៀបវារៈ និង/ឬកំណត់ហេតុនៃជំនួបទាំងនោះផង[៧៩]។ សំណើសុំ

---

[៧៦] *វេស្ដអាជ្ញា តទល់នឹង Prlić* និងអ្នកផ្សេងទៀត, សំណុំរឿងលេខ IT-04-74-AR65.24 សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ Jadranko Prlić ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើញត្តិរបស់គាត់សុំឱ្យមានការដោះលែងបណ្ដោះអាសន្ន ចុះថ្ងៃទី៨ ខែ មិថុនា ឆ្នាំ ២០១១ កថាខណ្ឌ៤ *ដោយលើកឡើងអំពី វេស្ដអាជ្ញា តទល់នឹង Vujadin Popović និង អ្នកផ្សេងទៀត,* សំណុំរឿងលេខ IT-05-88-AR65.10 សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ Radivoje Miletić ប្រឆាំងនឹងសេចក្ដីសម្រេចស្ដីពីញត្តិរបស់ Miletić សុំឱ្យមានការដោះលែងបណ្ដោះអាសន្ន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ៤-៥។ *វេស្ដអាជ្ញា តទល់នឹង Prlić និង អ្នកផ្សេងទៀត* IT-04-74-AR65.14 សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ Jadranko Prlić ប្រឆាំងនឹង *Décision Relative à la demande de mise en liberté provisoire de l’accusé Prlić* ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០០៩ ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៩ កថាខណ្ឌ៥-៦។ *វេស្ដអាជ្ញា តទល់នឹង Vujadin Popović និង អ្នកផ្សេងទៀត,* សំណុំរឿងលេខ IT-05-88-AR65.7 សេចក្ដីសម្រេចលើបណ្ដឹងចាត់របៀបរបស់ Vujadin Popović ប្រឆាំងនឹងសេចក្ដីសម្រេចលើញត្តិរបស់ Popović សុំឱ្យមានការដោះលែងបណ្ដោះអាសន្ន ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៨ កថាខណ្ឌ៦។

[៧៧] បណ្ដឹងជិតចិត្តជាបន្ទាន់ចំពោះលោកស្រីចៅក្រម Cartwright របស់ក្រុមមេធាវីការពារក្ដីរបស់ នួន ជា ឯកសារលេខ E137/2 ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១។

[៧៨] វិធាន៣៥(២)។

[៧៩] សំណើសុំឱ្យមានការស៊ើបអង្កេត (ជើងទំព័រត្រូវបានលុបចោល)។

ឲ្យស៊ើបអង្កេតចែងច្បាស់ថា "សំណើនេះពុំមែនជាបណ្តឹងជំទាស់"[៨០] ឡើយ ហើយតាមពិត មេធាវីការពារក្តីពុំបានប្តឹងជំទាស់ចៅក្រម Cartwright ទេ។ អង្គជំនុំជម្រះសាលាដំបូងបានខកខានទាំងស្រុងក្នុងការបែងចែកភាពខុសគ្នារវាងសំណើសុំឲ្យស៊ើបអង្កេត និងបណ្តឹងជំទាស់ស្របតាមវិធាន ៣៤។

៤៣. អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការចាត់ទុកដោយមិនត្រឹមត្រូវ និងបកស្រាយខុសចំពោះសំណើសុំឲ្យស៊ើបអង្កេតថាជាបណ្តឹងជំទាស់ស្របតាមវិធាន ៣៤ ហើយហេតុនេះបានសន្និដ្ឋានថា "សំណើរបស់មេធាវីការពារក្តី ពុំបានបំពេញនូវកម្រិតនៃលក្ខខណ្ឌតម្រូវ ស្តីពីភ័ស្តុតាង ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង៣៤ [ពាក់ព័ន្ធនឹងការស្តែងឲ្យឃើញនូវភាពលម្អៀង]"[៨១]។ ជាលទ្ធផលនៃកំហុសនេះ អង្គជំនុំជម្រះសាលាដំបូងមានកំហុសបន្ថែមទៀតដោយអនុវត្តបទដ្ឋានខុស (បទដ្ឋានយោងតាមវិធាន ៣៤ សម្រាប់ការកំណត់នូវការលេចឡើងនូវភាពលម្អៀង[៨២] ដើម្បីកំណត់ថាតើសំណើសុំឲ្យស៊ើបអង្កេតបំពេញតាមលក្ខខណ្ឌតម្រូវនៃភ័ស្តុតាងសម្រាប់ការស៊ើបអង្កេតដែរឬទេ។

៤៤. ការចាត់ទុកដោយខុសឆ្គងចំពោះសំណើសុំឲ្យស៊ើបអង្កេតរបស់អង្គជំនុំជម្រះសាលាដំបូង ថាជាបណ្តឹងជំទាស់ បង្កើតឲ្យមានជាការលេចឡើងនូវការជ្រៀតជ្រែកដោយចេតនាពិតប្រាកដទៅក្នុងកិច្ចការរដ្ឋបាលតុលាការ។ ដោយបានច្រានចោលការព្រួយបារម្ភដ៏សមហេតុផលរបស់មេធាវីការពារក្តី ទាក់ទិននឹងកិច្ចប្រជុំ *តែភាគីម្ខាង* រវាងចៅក្រមម្នាក់ និងព្រះរាជអាជ្ញាម្នាក់ អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានផ្តល់ទម្ងន់ណាមួយទៅលើភ័ស្តុតាងដែលបានបង្ហាញក្នុងសំណើសុំឲ្យស៊ើបអង្កេត។ ដោយមិនបាន យ៉ាងហោចណាស់ ជំរុញឲ្យលោកស្រីចៅក្រម Cartwright ផ្តល់នូវសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ (ដូចដែលចៅក្រមដទៃទៀតបានធ្វើរួចមកហើយពីមុន)[៨៣] អង្គជំនុំជម្រះសាលាដំបូងគ្រាន់តែយោងទៅសារអេឡិចត្រូនិកមួយរបស់អនុប្រធានរដ្ឋបាល

---

[៨០] *ដូចជើងទំព័រខាងលើ*។

[៨១] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ១២, ១៩។

[៨២] *សូមមើលជើងទំព័រខាងលើ* កថាខណ្ឌ១៣ *លើកឡើងពី រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Furundžija* សំណុំរឿងលេខ IT-95-17/1-A, សាលក្រម ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០ កថាខណ្ឌ១៨៩។

[៨៣] *សូមមើលផងដែរ* ចម្លើយតបទៅនឹងសំណើរបស់ អៀង សារី សុំឲ្យចាត់វិធានការសមស្រប ពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍ជាក់លាក់របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលប្រឆាំងនឹងឯករាជភាពរបស់ចៅក្រម Katinka Lahuis និង Rowan Downing របស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ២ ដែលចៅក្រម Downing និង Lahuis បានដាក់សារណាឆ្លើយតបទៅនឹងសំណើសុំឲ្យចាត់ "វិធានការសមស្រប" ជាជាងបណ្តឹងជំទាស់ *ដោយផ្ទាល់*។

ដែលអះអាងថា បានដោះស្រាយយ៉ាងគ្រប់គ្រាន់នឹងការព្រួយបារម្ភរបស់មេធាវីការពារក្ដី[៨៤]។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបានយកមកអនុវត្តបទដ្ឋានត្រឹមត្រូវ ពោលគឺបទដ្ឋាននៃវិធាន ៣៥ ចំពោះសំណើសុំឱ្យស៊ើបអង្កេត អង្គជំនុំជម្រះប្រាកដជាមានកាតព្វកិច្ចក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការស៊ើបអង្កេតឱ្យបានពេញលេញថាតើ លោកស្រីចៅក្រម Cartwright និង លោក Cayley បានជ្រៀតជ្រែកដោយចេតនាពិតប្រាកដទៅក្នុងកិច្ចការរដ្ឋបាលតុលាការ ឬយ៉ាងណា។

៤៥. វិធាន ៣៥ តម្រូវឱ្យមាន "ហេតុផលអាចឱ្យជឿបាន"[៨៥] ថា ការជ្រៀតជ្រែកទៅក្នុងកិច្ចការរដ្ឋបាលតុលាការបានកើតឡើង។ លក្ខខណ្ឌតម្រូវនៃភ័ស្តុតាងនេះត្រូវបានចាត់ទុកថាជា "បទដ្ឋានដែលមានលក្ខណៈស្រាលបំផុត"[៨៦]។ សំណើសុំឱ្យស៊ើបអង្កេតបានបង្ហាញថា៖ **ក.** កិច្ចប្រជុំ*តែភាគីម្ខាង* រវាងលោកស្រីចៅក្រម Cartwright និងលោក Cayley បានកើតឡើងតាមកាលកំណត់ដោយគ្មានការព្រមព្រៀងពីភាគីផ្សេងទៀតក្នុងសំណុំរឿង ០០២ ឡើយ[៨៧] **ខ.** លោក Cayley ដែលកាលពីមុនធ្លាប់មានវត្តមាន និងបន្តមានវត្តមាននៅចំពោះមុខលោកស្រីចៅក្រម Cartwright តទៅទៀត ក្នុងសំណុំរឿង០០២[៨៨] និង **គ.** គ្មានមូលដ្ឋានច្បាប់ច្បាស់លាស់សម្រាប់កិច្ចប្រជុំ*តែភាគីម្ខាង*ទាំងនេះ[៨៩]។ ពីព្រោះថា កិច្ចប្រជុំ*តែភាគីម្ខាង* ត្រូវបានហាមប្រាមទាំងក្នុងច្បាប់ជាតិ និងច្បាប់អន្តរ

---

[៨៤] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ២០។

[៨៥] វិធាន៣៥(២)។

[៨៦] *សូមមើល* សាលដីកាលើកទីពីរលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឱ្យកោះហៅសាក្សី, ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១០, ឯកសារលេខ D314/1/12, កថាខណ្ឌ ៣៧៖ "បទដ្ឋានដែលតម្រូវឱ្យមាន*មូលហេតុអាចឱ្យជឿបាន* គឺជាបទដ្ឋានដែលមានលក្ខណៈស្រាលបំផុត ហើយនឹងអាចនាំឱ្យមានការស៊ើបសួរពីសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះណាមួយ។ លក្ខណៈទូលំទូលាយនៃបទដ្ឋានមួយនេះ ត្រូវបានបញ្ជាក់ដោយការប្រើប្រាស់ពាក្យ *អាច* នៅក្នុងវិធាន ៣៥(២) នៃវិធានផ្ទៃក្នុង។ ការរកឃើញថា មានហេតុផលជឿ មិនតម្រូវឱ្យមានសេចក្តីសម្រេចណាមួយទៅលើភាពត្រឹមត្រូវនៃការចោទប្រកាន់ ឬការសង្ស័យថាមានការជ្រៀតជ្រែកនោះទេ។ ប៉ុន្តែចំពោះការរកឃើញថា បទដ្ឋាននៃការមានហេតុផលជឿត្រូវបានបំពេញ កតម្រូវឱ្យ ស.ច.ស ឬអង្គជំនុំជម្រះសន្និដ្ឋានថា មានមូលដ្ឋានជាក់លាក់ ឬ*មូលហេតុ*ដែលជាមូលដ្ឋាននៃ*ជំនឿ*របស់ខ្លួន។ មូលដ្ឋានជាក់លាក់ ឬ*មូលហេតុ* ត្រូវតែបង្ហាញឱ្យឃើញ ដោយផ្អែកលើការពិនិត្យលើការចោទប្រកាន់ ឬការសង្ស័យ ដែលការពិនិត្យនេះ អាចមានលក្ខណៈជាអត្តនោម័ត"។

[៨៧] សំណើសុំឱ្យស៊ើបអង្កេត, កថាខណ្ឌ ៤, ៩, ១០, ២៣។

[៨៨] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ២៥។

[៨៩] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ២៤។

ជាតិ ហើយសំណើសុំឲ្យស៊ើបអង្កេតបានបង្កើត "ហេតុផលអាចឲ្យជឿបាន" ថា ការជ្រៀតជ្រែកដោយចេតនាពិតប្រាកដទៅក្នុងកិច្ចការរដ្ឋបាលតុលាការ ពិតជាបានកើតមាន។

៤៦. អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយខកខានមិនបានដឹកនាំការស៊ើបសួរ ស្របតាមវិធាន ៣៥ ដើម្បីកំណត់ថាតើមានមូលដ្ឋានគ្រប់គ្រាន់ ឬយ៉ាងណា ក្នុងការផ្តួចផ្តើមដំណើរការនីតិវិធីពាក់ព័ន្ធនឹងការជ្រៀតជ្រែកដោយចេតនាពិតប្រាកដទៅក្នុងកិច្ចការរដ្ឋបាលតុលាការ[៥០]។ តាមរយៈការកំណត់សំណើសុំឲ្យស៊ើបអង្កេតដោយមិនត្រឹមត្រូវ និងការអនុវត្តបទដ្ឋានកម្រិតលក្ខខណ្ឌតម្រូវនៃភ័ស្តុតាងដោយមិនត្រឹមត្រូវ អង្គជំនុំជម្រះសាលាដំបូងមានកំហុសទាំងលើអង្គហេតុ ឬបានបំពានឆន្ទានុសិទ្ធិរបស់ខ្លួន ដូច្នេះបានជ្រៀតជ្រែកដោយចេតនាពិតប្រាកដទៅក្នុងកិច្ចការរដ្ឋបាលតុលាការ។ ការធ្វើបែបនេះ អង្គជំនុំជម្រះសាលាដំបូងបានខកខានមិនបានបំពេញកាតព្វកិច្ចស្របតាមរដ្ឋធម្មនុញ្ញរបស់ខ្លួន ក្នុងការធានានូវការជំនុំជម្រះប្រកបដោយយុត្តិធម៌សម្រាប់ជនជាប់ចោទ។

## VI. សេចក្តីសន្និដ្ឋាន និងសំណូមពរ

៤៧. អង្គជំនុំជម្រះសាលាដំបូងបានជ្រៀតជ្រែកដោយចេតនាពិតប្រាកដទៅក្នុងកិច្ចការរដ្ឋបាលតុលាការ ដោយខកខានមិនបានស៊ើបអង្កេតទៅលើកិច្ចប្រជុំ*តែភាគីម្ខាង*រវាងលោកស្រី ចៅក្រម Cartwright លោក Cayley និងអ្នកផ្សេងៗទៀត។ អង្គជំនុំជម្រះធ្វើបែបនេះ ដោយកំណត់ប្រភេទសំណើសុំឲ្យស៊ើបអង្កេតដោយមិនត្រឹមត្រូវ ដែលធ្វើឲ្យអាចការពារលោកស្រីចៅក្រម Cartwright និងលោក Cayley និងរារាំងមេធាវីការពារក្តីមិនឲ្យអាចបញ្ជាក់បានថាតើ មានហេតុផលសមស្របសម្រាប់បណ្តឹងជំទាស់លោកស្រីចៅក្រម Cartwright ដោយអនុលោមតាមវិធាន ៣៤ ដែរឬយ៉ាងណា។ ដោយសារតែការស្ទាក់ស្ទើររបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការស្វែងរកការពិត ដូចបានបញ្ជាក់តាមរយៈការយោងរបស់ចៅក្រមប្រធាន និល ណុន ទៅលើសារអេឡិចត្រូនិកមួយផ្ញើជូនដោយលោក Rosandhaug ដោយថាសារនេះបានឆ្លើយតបគ្រប់គ្រាន់ចំពោះការព្រួយបារម្ភរបស់មេធាវីការពារក្តី[៥១] អង្គជំនុំជម្រះតុលាការកំពូលគួរអនុវត្តភារកិច្ចដែលអង្គជំនុំជម្រះសាលាដំបូងបដិសេធបំពេញ និងដឹកនាំការស៊ើបអង្កេតដោយខ្លួនឯងទៅលើកិច្ចប្រជុំ*តែភាគីម្ខាង*ទាំងនោះ។

---

[៥០] សូមមើល វិធាន៣៥(២)(ខ)។

[៥១] *សូមមើល* ប្រតិចារឹកនៃការជំនុំជម្រះ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារលេខ E1/13.1 ទំព័រ១៤។

**អាស្រ័យហេតុនេះ** យោងតាមហេតុផលដូចដែលបានលើកឡើងខាងលើ មេធាវីការពារក្តីសូមស្នើដោយក្តីគោរពដល់អង្គជំនុំជម្រះតុលាការកំពូលមេត្តា៖

ក) សម្រេចថា បណ្តឹងសាទុក្ខនេះអាចទទួលយកបាន។

ខ) អនុញ្ញាតឲ្យមានសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈ។

គ) ទុកជាមោឃៈសេចក្តីសម្រេចដែលត្រូវបានជំទាស់ និង

ឃ)ស៊ើបអង្កេតទៅលើកិច្ចប្រជុំ*តែភាគីម្ខាង*រវាងលោកស្រីចៅក្រម Cartwright សហព្រះរាជអាជ្ញាអន្តរជាតិ និងអ្នកផ្សេងៗទៀត។

សូមចៅក្រមអង្គជំនុំជម្រះតុលាការកំពូល ទទួលយកបណ្តឹងសាទុក្ខនេះដោយក្តីគោរព។

ចុះហត្ថលេខានៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១២

_______________ _______________

**អាង ឧត្តម** **Michael G. KARNAVAS**

សហមេធាវីរបស់លោក **អៀង សារី**